ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម

## English Vocabulary Learning Strategies Used by High School Students in Kampong Cham Province

ដោយ/by

**អៀង គឹមឈាន**

EANG KEMCHHEAN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម

# English Vocabulary Learning Strategies Used by High School Students in Kampong Cham Province

ដោយ/by

**អៀង គីមឈាន**

EANG KEMCHHEAN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេស៖ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖** **បណ្ឌិត ម៉ុក សារ៉ុម**
**សាស្ត្រាចារ្យដឹកនាំរង៖** **ចាប រតនា**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦២៩ **អយក.** ប្រក
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុធន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

**អៀង គឹមឈាន**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម ជាសាស្ត្រាចារ្យដឹកនាំ

លោក ចាប រតនា ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក អៀង គីមឈាន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម**" ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

| | |
|---|---|
| ................................ | ................................ |
| **បណ្ឌិត ម៉ុក សារ៉ុម** | **លោក ចាប រតនា** |
| អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រចារ្យ **បណ្ឌិត ម៉ុក សារ៉ុម** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យជំនួយ **ចាប រតនា** និងមិត្តរួមជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្តតាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំសូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ បងប្អូន និងភរិយារបស់ខ្ញុំដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។ ខ្ញុំក៏សូមឧទ្ទិសនូវស្នាដៃនៃការសិក្សាស្រាវជ្រាវនេះជូនចំពោះអ្នកម្តាយ កែវ លុយ ដែលបានបែកកាយទៅកាន់លោកខាងមុខហើយក្តីសូមឲ្យអ្នកម្តាយទទួលបាននូវអ្វីដែលជាការខិតខំបណ្តុះបណ្តាលកូនឲ្យមានថ្ងៃនេះផងចុះ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយាខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

ការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទ (អ្នកសិក្សាភាសាបរទេស) ត្រូវបានពិពណ៌នាជាជំហានដែលអនុវត្តន៍ដោយអ្នកសិក្សា ដើម្បីបង្កើនការលូតលាស់ពាក្យរបស់ពួកគេដែលនៅទីបំផុតអាចឲ្យពួកគេដំណើរការបានយ៉ាងមានប្រសិទ្ធភាពនៅក្នុងភាសាអង់គ្លេស។ ការរៀនសូត្រវាក្យសព្ទ គឺជាបញ្ហាប្រឈមដ៏ធំមួយក្នុងចំណោមអ្នកសិក្សាភាសាបរទេសដែលប្រឈមមុខក្នុងកំឡុងពេលនៃការរៀនសូត្រភាសា (Ghazal, 2007)។ ការស្រាវជ្រាវមួយនេះមានបំណងស្វែងរក និងបង្ហាញឲ្យឃើញពីស្ថានភាពជាក់ស្តែងនៃ ការប្រើយុទ្ធសាស្ត្រក្នុងរៀនវាក្យសព្ទរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តកំពង់ចាម និងបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការរៀនភាសាអង់គ្លេសសព្វថ្ងៃ។ ភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យដែលអាចជឿទុកចិត្តបាននោះគឺសិស្សថ្នាក់ទី ១២ ដែលរៀននូវបណ្តុំមុខវិជ្ជាផ្សេងគ្នាមាន ចំនួន ៣៥៥នាក់ ស្រី ១៩២នាក់ ក្នុងនោះសិស្សថ្នាក់វិទ្យាសាស្ត្រចំនួន ១៥៦នាក់ ស្រីចំនួន ៨៦នាក់ និងវិទ្យាសាស្ត្រសង្គមចំនួន ១៩៩នាក់ ស្រីចំនួន ១០៦នាក់ ចេញពីវិទ្យាល័យចំនួន ០៥ ក្នុងស្រុកបាធាយ ក្នុងខេត្តកំពង់ចាម។

ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើឧបករណ៍ជាកម្រងសំណួរជ្រើសរើសដែលដកស្រង់ចេញមកពីនិក្ខេបបទរបស់ លោក Richard A. LaBontee, Jr (2019) ដែលមាន ៦៩ ចំណុច ចែកចេញជា ៧ផ្នែក។ អ្នកស្រាវជ្រាវដកស្រង់កម្រងសំណួរជ្រើសរើសចំនួន ៤០ ចំណុច បែងចែកជា ៤ ផ្នែក៖ ផ្នែកទី១៖ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២៖ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣៖ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះអាចបង្ហាញដូចខាងក្រោម៖

១) ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទតាមរយៈ (ចំណុចទី៣៦) ការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ គឺមានកម្រិត មធ្យមខ្ពស់ ៣.៥២ (M=3.52) បន្ទាប់មកទៀតគឺ (ចំណុចទី២២) ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ដែលមានកម្រិតមធ្យម ៣.៤៣ (M=3.43) និងកម្រិតខ្ពស់ចុងក្រោយគឺ (ចំណុចទី៥) ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.២៨ (M=3.28)។ ការសិក្សានេះក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរ អំពីការប្រើយុទ្ធសាស្ត្ររៀនតាមរយៈ (ចំណុចទី២៤) ការបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨៤ (M=1.84) បន្ទាប់មក (ចំណុចទី៧) ការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៩៧ (M=1.97) និងចំណុចចុងក្រោយគឺ (ចំណុចទី២៩) ការរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យម ១.៩៩ (M=1.99)។ ទន្ទឹមគ្នានេះផងដែរលទ្ធផលសិក្សាជាផ្នែកក៏បង្ហាញឲ្យឃើញថា ផ្នែកទី៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យម

ខ្ពស់ជាងគេ ២.៧០ (M=2.70) បន្ទាប់ទៀត ផ្នែកទី៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦២ (M=2.62) បន្ទាប់មកទៀតផ្នែកទី១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៨ (M=2.58) ចំណែកឯផ្នែកទី២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៥០ (M=2.៥០)។

២) បើប្រៀបធៀបសិស្សដែលរៀននៅបណ្តុំមុខវិជ្ជាផ្សេងគ្នា (ថ្នាក់វិទ្យាសាស្ត្រ និងសង្គម) និងភេទខុសគ្នា ការស្រាវជ្រាវបង្ហាញឲ្យឃើញថា សិស្សរៀនបណ្តុំវិទ្យាសាស្ត្រ និងសង្គមប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស (p>0.0៦០) និងសិស្សមានភេទខុសគ្នានៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស (p>0.0៦៥)។ លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សដែលរៀននៅបណ្តុំមុខវិជ្ជាផ្សេងគ្នា (ថ្នាក់វិទ្យាសាស្ត្រ និងសង្គម) និងភេទខុសគ្នាជារួម និងតាមផ្នែក ប្រើប្រាស់យុទ្ធសាស្ត្រមិនខុសគ្នាទេ។

ជារួមការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាមមានលក្ខណៈដូចគ្នា ដោយសារតែនៅមធ្យមសិក្សាទុតិយភូមិ ចំនួនម៉ោងសិក្សាភាសាអង់គ្លេស សៀវភៅសិក្សាគោល កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនដូចគ្នា ចំណែកឯគ្រូបង្រៀននៅតាមសាលាក៏មិនសូវមានការបំប៉នន្ធូវវិធីសាស្ត្រថ្មីៗដែរ។

## Abstract

The use of vocabulary learning strategies (foreign language learners) is described as steps taken by learners to enhance their word development which ultimately enable them to function effectively in English. Vocabulary learning is a major challenge among foreign language learners faced during the course of language learning (Ghazal, 2007). This research aims to explore and illustrate the realities of using the vocabulary learning strategies of Cambodian high school students in Kampong Cham and the challenges associated with learning English today. The sample that the researchers considered to be able to obtain reliable data was that of the grade-12 students taking different courses (strands): 355 students, 192 females including 156 science-class students, 86 girls and 199 social-class students, 106 females from 5 high schools in Batheay district in Kampong Cham province.

In this study, researchers used the instrument of questionnaire selection, based on Richard A. LaBontee, Jr.'s (2019) thesis, consisting of 69 points divided into seven sections. Researchers cite a 40-point questionnaire, divided into four ps: Part 1: Production Based (with 6 points ranging from 1 to 6), Part 2: Investigation Based (with 11 points from 7 to 17) Part 3: Lexical Associative (with 13 points from 18 to 30) and Part 4: Context Associative (with 10 points from 31 to 40).

The results of this research are as follows:

1) The results of this study showed that using the vocabulary learning strategies through (Item 36), asking teachers and peers words I did not know, a high average of 3.52 (M = 3.52), thereafter (Item 22) I try to memorize words with spelling, an average of 3.43 (M = 3.43) and the last high is (Item 5) I read the word aloud or learn by heart over and over to remember it, moderating 3.28 (M = 3.28). The study also showed the lowest levels of learning strategies through (Item 24) dividing into the prefix and the suffix to help me learn it quickly, with an average of 1.84 (M = 1.84). Then (Item 7), the list of words in different order to learn it in other ways averaged 1.97 (M = 1.97), and the last was (Item 29) organizing the words by word types (Verb, Adjective, Noun .........) were moderately 1.99 (M = 1.99). At the same time, cross-sectional study also showed that Part 4: **Context Associative**

had the highest mean of 2.70 (M = 2.70), followed by Part 3: **Lexical Associative** with an average of 2.62 (M = 2.62) followed by Part 1: **Production Based** with a mean of 2.58 (M = 2.58), whereas part 2: **Investigation Based** was a limited part of the lowest average which has an average rate 2.50 (M = 2.50).

2) Comparing students studying in different subject areas (science and social class) and different genders, research shows that students in science and society use English vocabulary learning strategies ($p > 0.060$) and students of different gender at the high school level use the English vocabulary learning strategies ($p > 0.065$). The results indicate that the vocabulary learning strategies of students in different subject areas (science and social class) and of different genders overall and across strategies are not different.

To sum up, the use of English language learning strategies of Cambodian students at the high school level in Kampong Cham is the same because in high school, the number of hours of English language, textbooks, curriculum and teaching methods is the same as that of teachers in schools. There is also less training of new methods.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន....i
លិខិតបញ្ជាក់....ii
សេចក្តីថ្លែងអំណរគុណ....iii
មូលន័យសង្ខេប....iv
Abstract ....vi
បញ្ជីតារាង ....xi
បញ្ជីអក្សរកាត់....xii
ជំពូកទី១ ....១
សេចក្តីផ្តើម ....២
១.១- លំនាំបញ្ហានៃការស្រាវជ្រាវ....២
១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ....៣
១.៣- គោលបំណងនៃការស្រាវជ្រាវ....៥
១.៤- សំណួរស្រាវជ្រាវ....៥
១.៥- សារៈសំខាន់នៃការស្រាវជ្រាវ....៥
១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ....៦
១.៦.១- វិសាលភាពនៃការស្រាវជ្រាវ....៦
១.៦.២- ដែនកំណត់នៃការស្រាវជ្រាវ....៦
១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ....៦
ជំពូកទី២ ....៩
រំលឹកទ្រឹស្តី ....៩
២.១- និយមន័យ....៩
២.១.១- យុទ្ធសាស្ត្រ....៩
២.១.២- វាក្យសព្ទ....៩
២.២- ការរៀនវាក្យសព្ទភាសាអង់គ្លេស....១០
២.៣- សារៈសំខាន់នៃការរៀនវាក្យសព្ទ....១១
២.៤- ការប្រើយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទ....១៣

ជំពូកទី៣ ............................................................................................................................១៦
វិធីសាស្ត្រស្រាវជ្រាវ............................................................................................................................១៦
៣.១- ប្រជាជន និងភាគសំណាក.......................................................................................................១៦
៣.១.១- ប្រជាជន.............................................................................................................................. ១៦
៣.១.២- ភាគសំណាក ........................................................................................................................ ១៦
៣.២- ឧបករណ៍ស្រាវជ្រាវ.................................................................................................................. ១៧
៣.៣- ដំណើរការប្រមូលទិន្នន័យ .........................................................................................................១៨
៣.៤- ការវិភាគទិន្នន័យ .....................................................................................................................១៩
៣.៥- ក្រមសីលធម៌នៃការស្រាវជ្រាវ ...................................................................................................១៩
ជំពូកទី៤ ............................................................................................................................ ២១
លទ្ធផលការស្រាវជ្រាវ ........................................................................................................................ ២១
៤.១- លទ្ធផលការស្រាវជ្រាវសំណួរទី១៖ តើយុទ្ធសាស្ត្រសិក្សាវាក្យសព្ទអ្វីដែលសិស្សប្រើ?................ ២១
៤.២- តើមានការប្រើប្រាស់យុទ្ធសាស្ត្រសិក្សាវាក្យសព្ទខុសគ្នារវាងសិស្សរៀនបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម និងសិស្សដែលមានភេទខុសគ្នាឬទេ?........................................................៤៤
ជំពូកទី ៥ ............................................................................................................................៤៨
សេចក្តីសន្និដ្ឋាន ការពិភាក្សា និងអនុសាសន៍.....................................................................................៤៨
៥.១- សេចក្តីសង្ខេបលទ្ធផលការស្រាវជ្រាវ ..........................................................................................៤៨
៥.២-ការពិភាក្សាការស្រាវជ្រាវ...............................................................................................................៤៩
៥.៣- អនុសាសន៍..................................................................................................................................៥០
៥.៣.១. អនុសាសន៍សម្រាប់ការអនុវត្ត........................................................................................ ៥០
៥.៣.២. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត .............................................................................. ៥០
សេចក្តីសន្និដ្ឋាន................................................................................................................................៥០
ឯកសារយោង ................................................................................................................................... ៥២
ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា...................................................៥៥
ឧបសម្ព័ន្ធ ............................................................................................................................៥៥
ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម ................................៥៩
ឧបសម្ព័ន្ធទី ៣៖ កម្រងសំណួរ ............................................................................................................៦១

ឧបសម្ព័ន្ធទី ៤៖ Reliability ..................................................................................................... ៦៥
ឧបសម្ព័ន្ធទី ៥៖ Mean និង Standard Deviation.................................................................... ៦៧
ឧបសម្ព័ន្ធទី ៦៖ Independent Sample-t Test........................................................................ ៦៩
ឧបសម្ព័ន្ធទី ៧៖ ............................................................................................................... ៧៤
១-គណៈកម្មការមេប្រយោគ........................................................................................................ ៧៤
២-គណៈកម្មការការពារនិក្ខេបបទ ............................................................................................. ៧៥
៣-គណៈកម្មការកណ្តាល ........................................................................................................ ៧៦

# បញ្ជីតារាង


តារាងទី១៖ ភេទ បណ្ដុំសិក្សា សមត្ថភាពភាសាអង់គ្លេសនៅតាមវិទ្យាល័យទាំង ៥..........................១៦

តារាងទី២៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ (N= 355).....................................................២១

តារាងទី៣៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) ...............................២៥

តារាងទី៤៖ មធ្យម គម្លាតស្តង់ដារនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិតាមភេទ (N=៣៥៥) ..........................................................................២៨

តារាងទី៥៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥)តាមភេទ ................... ៣២

តារាងទី៦៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) តាមបណ្ដុំមុខវិជ្ជា ........ ៣៣

តារាងទី៧៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) .............................. ៣៧

តារាងទី៨៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) ...............................៣៩

តារាងទី៩៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) ...............................៤៣

តារាងទី១០ ៖ភាពដូចគ្នា និងភាពខុសគ្នាការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាតាមបណ្ដុំវិទ្យាសាស្ត្រ និងសង្គម..................................................៤៤

តារាងទី១១ ៖ភាពដូចគ្នា និងភាពខុសគ្នាការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាតាមភេទ ប្រុស និងស្រី .........................................................៤៥

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ១. | វិ.សអតជហស បាធាយ | ៖ វិទ្យាល័យ សម្ដេចអគ្គមហាសេនាបតី តេជោហ៊ុន សែនបាធាយ |
| ២. | វិ.ហណហ ព្រៃញា | ៖ វិទ្យាល័យ ហោ ណាំហុង ព្រៃញា |
| ៣. | វិ.សតហស សណ្ដោក | ៖ វិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សណ្ដោក |
| ៤. | វិ.ហស ជើងផ្នុក | ៖ វិទ្យាល័យ ហ៊ុន សែន ជើងផ្នុក |
| ៥. | វិ.ហស សង្កើប | ៖ វិទ្យាល័យ ហ៊ុន សែន សង្កើប |

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

ភាសាអង់គ្លេស គឺជាភាសាមួយដែលត្រូវបានគេប្រើប្រាស់ពាសពេញពិភពលោកអស់រយៈពេលជាងមួយសតវត្សហើយៗវាត្រូវគេទទួលស្គាល់នៅក្នុងបណ្តាប្រទេសជាច្រើននៅជុំវិញពិភពលោក។ មនុស្សនិយាយភាសា អង់គ្លេសជាជនជាតិដើមប្រមាណជា ៣៣០ លាននាក់ និងប្រហែលជា៤៣០ លាននាក់ទៀតមិនមែនជាជនជាតិដើម (Crystal 2003)។ មានមនុស្សជាងពាក់កណ្តាលពិភពលោកចេះនិយាយពីរឬច្រើនភាសា (Grosjean 2010)។ ការប្រើប្រាស់ភាសាអង់គ្លេសវាបានផ្តល់ផលជាច្រើនដល់ប្រជាជននៅលើសកលលោកសម្រាប់ការប្រាស្រ័យទាក់ទងគ្នា ឬអាចនិយាយបានថាភាសាអង់គ្លេសគឺជាភាសាយានដ៏សំខាន់មួយសម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងទំនាក់ទំនងផ្សេងៗនៅក្នុងយុគសម័យសាកលភាវូនីយកម្មនាពេលបច្ចុប្បន្ន និងអនាគតដោយសារតែភាសាអង់គ្លេសត្រូវបានគេប្រើច្រើនជាងគេនៅលើពិភពលោក (Crystal, 1997)។ យ៉ានណាមិុញ Naisbitt និង Aburdence (1990) បានសង្កត់ធ្ងន់ទៅលើតួនាទីភាសាអង់គ្លេសទាក់ទងនឹងភាសាក្នុងស្រុកថាៈ ភាសាអង់គ្លេស គឺមិនមែនកំពុងតែជំនួសភាសាក្នុងស្រុកនោះដោយអនុញ្ញាតឲ្យជនចម្លែកៗអាចធ្វើការប្រាស្រ័យទាក់ទងគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតបាន ហើយនឹងបើកទ្វារចំហរដល់ពិភពលោកដើម្បីចាប់យកឱកាស ព្រមទាំងពង្រឹងផ្នត់គំនិតទទួលយកគំនិតថ្មី។ ភាសាអង់គ្លេស គឺជាភាសាការងារផ្លូវការតែមួយគត់នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំងដល់ប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍន៍ទុនភាសាអង់គ្លេស (Clayton, 2007)។

ដោយឡែកនៅក្នុងបរិបទកម្ពុជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សាក្នុងឆ្នាំ១៩៨៩ (Vira, 2002)។ មុននឹងការដាក់ចេញឲ្យប្រើភាសាអង់គ្លេស ភាសាបារាំងគឺជាភាសាបរទេសដែលបានលេចធ្លោនៅកម្ពុជា ក៏ដូចជាការដាក់បញ្ចូលក្នុងកម្មវិធីសិក្សា។ គួរកត់សម្គាល់ផងដែរថានៅក្នុងប្រទេសកម្ពុជា ភាសាអង់គ្លេសមិនត្រឹមតែត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសាលារដ្ឋតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ត្រូវបានគេប្រើប្រាស់សម្រាប់មុខវិជ្ជាជាក់លាក់ជាច្រើននៅតាមសាកលវិទ្យាល័យនានា និងទីផ្សារការងារផងដែរ។

ដោយមានការខិតខំ និងយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលអង់គ្លេសតាមរយៈគម្រោងនៃការបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសម្រាប់កម្ពុជា (CAMSET) បានផលិតចេញនូវសៀវភៅសិក្សាគោលសម្រាប់សាលាមធ្យមសិក្សាជាលើកដំបូង ដែលបានដាក់ឲ្យប្រើប្រាស់នៅចុងទសវត្សឆ្នាំ១៩៩០ និងដើមទស្សវត្សឆ្នាំ២០០០ ក្នុងគោលបំណងកសាងសមត្ថភាពសិស្សានុសិស្ស កម្ពុជាដើម្បីបម្រើឲ្យសេចក្តីត្រូវការរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។ គម្រោងនេះរៀបចំដោយ CfBT Education Services ។ តាមរយៈគម្រោងនេះ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសអង់គ្លេស (CFID) បានផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ ការ

រៀបចំប្រព័ន្ធអធិការកិច្ចសាលារៀន និងបណ្ដុះបណ្ដាលផ្នែកអ្នកនិពន្ធ ផ្នែករៀបរៀង ព្រមទាំងបោះពុម្ព និងផ្នែកចែកផ្សាយសៀវភៅទាំងនេះផងដែរ។

ដោយការមើលឃើញពីសារៈសំខាន់នៃការប្រើប្រាស់ភាសាអង់គ្លេស សាលាភាសាអង់គ្លេសឯកជនក៏ចាប់ផ្ដើមបង្កើតឡើង និងរីកដុះដាលយ៉ាងច្រើននៅទូទាំងប្រទេសកម្ពុជា ជាពិសេសក្នុងរាជធានីភ្នំពេញ និងទីរួមខេត្តនានា រហូតដល់មានសាលាមួយចំនួនជ្រើសរើសយកភាសាអង់គ្លេស ជាភាសាយានសម្រាប់ការបង្រៀនចំណេះដឹងទូទៅលើគ្រប់មុខវិជ្ជាទាំងអស់ថែមទៀតផង។ តាមរយៈរបាយការណ៍បូកសរុបវង្វាយតម្លៃការអប់រំឆ្នាំសិក្សា២០១៦-២០១៧ និងទិសដៅឆ្នាំ២០១៨-២០១៩, (២០១៧) បង្ហាញថាសាលាអន្តរជាតិចំនួន ៣ នៅរាជធានីភ្នំពេញបានអនុវត្តតាមកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំយុវជន និងកីឡានិងជ្រើសរើសយកការបង្រៀនគ្រប់មុខវិជ្ជាជាភាសាអង់គ្លេស។ ហើយមានសាលាអន្តរជាតិចំនួន៧ទៀតដែលអនុវត្តន៍កម្មវិធីសិក្សាបរទេសដោយយកភាសាអង់គ្លេសជាយាន។ ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការរៀន និងបង្រៀនភាសាអង់គ្លេសតាមរយៈការកែប្រែកម្មវិធីសិក្សាភាសាអង់គ្លេស នៅតាមសាលារដ្ឋដោយឲ្យសិស្សចាប់ផ្ដើមរៀនភាសានេះតាំងពីថ្នាក់ទី៤ នៅបឋមសិក្សា (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១២) ហើយក្រសួងក៏បានធ្វើការកែប្រែសៀវភៅសិក្សាគោលភាសាអង់គ្លេសផងដែរ (Tweed និង Som, 2015) ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសាកលភាវូនីយកកម្ម ទំនាក់ទំនង បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ វប្បធម៌ និងប្រព័ន្ធសេដ្ឋកិច្ចចំរុះត្រូវបានចែករំលែកពីមួយទៅមួយដែលត្រូវបានធ្វើឡើងជាភាសាអង់គ្លេស។ ភាសាអង់គ្លេសត្រូវបានគេបែងចែកជាភាសាកំណើត ភាសាទីពីរ និងភាសាបរទេសដែលត្រូវប្រើប្រាស់ពាសពេញពិភពលោកដើម្បីបំពេញតាមតម្រូវការនៃការប្រើប្រាស់ ហេតុនេះហើយវាបានក្លាយជាឧបករណ៍ភ្ជាប់ទំនាក់ទំនងសម្រាប់សាកលភាវូនីយកម្មយ៉ាងទូលំទូលាយ។ នៅក្នុងប្រទេសកម្ពុជាភាសាអង់គ្លេសចាប់ផ្ដើមពេញនិយមសម្រាប់សិស្សានុសិស្សកម្ពុជាចាប់តាំងពីការដាក់ចេញនូវគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា (EFA) ពីរដ្ឋាភិបាលនៅឆ្នាំ១៩៩០ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅឆ្នាំ១៩៩១ វត្តមានរបស់អាជ្ញាធររបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) នៅអំឡុងឆ្នាំ១៩៩២-១៩៩៣ ការដាក់បញ្ចូលសេដ្ឋកិច្ចសាកលក្នុងតំបន់ សហគមន៍ ជំនួយអន្តរជាតិ (Clayton, 2009) និងសមាជិកភាពពេញសិទ្ធិនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅឆ្នាំ ១៩៩៩ (Igawa, 2008)។ ភាសាអង់គ្លេសត្រូវបានគេជ្រើសរើសជាភាសាផ្លូវការតែមួយគត់ សម្រាប់ការទាក់ទងនៅក្នុងសមាគមនេះ ចំពោះវិស័យនយោបាយ វិស័យសេដ្ឋកិច្ច និងវិស័យផ្សេងៗទៀត (Igawa, 2008)។ ទន្ទឹមគ្នានេះផងដែររដ្ឋាភិបាល និងប្រជាជនកម្ពុជាបានជ្រើសរើស និងប្រើប្រាស់ភាសាអង់គ្លេសដើម្បីទំនាក់ទំនង និងប្រកបអាជីវកម្មជាមួយគ្នា អង្គការ និងក្រុមហ៊ុនបរទេសផ្សេងៗទៀត។ នេះសបញ្ជាក់ឲ្យឃើញច្បាស់ពីគោលនយោបាយ និងផលប៉ះពាល់នៃការប្រើភាសាទៅលើជីវភាពរស់នៅរបស់ប្រជាជន ការអប់រំ និងអនាគតនៃប្រទេសដែលកំពុងតែផ្លាស់ប្ដូរ (Igawa, 2008)។

ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានដឹងអំពីចំណាប់ចំណូលចិត្តរបស់ប្រជាជនកម្ពុជាក៏ដូចជាសិស្ស និងនិស្សិតអំពីភាសាបរទេសដែលពួកគេត្រូវការ និងចង់រៀន ទើបក្រសួងបានខិតខំរិះរកនូវ

មធ្យោបាយផ្សេងៗដើម្បីដាក់ឲ្យមានការសក្សាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា។ ប៉ុន្តែការសិក្សាភាសាអង់គ្លេសត្រូវចាប់ផ្ដើមពីមូលដ្ឋានធនធានទាបបំផុត ដោយគ្មានកម្មវិធី គ្មានសៀវភៅសិក្សាគោល ចំណែកឯគ្រូបង្រៀនភាសាអង់គ្លេសនៅកម្ពុជាមានចំនួនតិចតួច (Pith, 1996)។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សាសាលាមធ្យមសិក្សារដ្ឋចាប់តាំងពីឆ្នាំ១៩៨៩ (Vira, 2002)។

ភាសាអង់គ្លេសត្រូវបានប្រើសម្រាប់ការបង្រៀនជាភាសាបរទេសរយៈពេល ៣ ឆ្នាំ នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង៣ ឆ្នាំទៀតនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ សិស្សទាំងអស់ត្រូវបានបង្រៀនភាសាអង់គ្លេសរយៈពេល ៦ ឆ្នាំ មុនពេលពួកគេបញ្ចប់ថ្នាក់វិទ្យាល័យ។ សិស្សដែលមានកម្រិតជំនាញភាសាអង់គ្លេសកម្រិតខ្ពស់ពីវិទ្យាល័យមក ពួកគេមានឱកាសទទួលបានភាពជោគជ័យនៅកម្រិតសាកលវិទ្យាល័យជាង (Nith, 2004)។

នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឲ្យប្រើសៀវភៅស៊េរី English for Cambodia (ភាសាអង់គ្លេសសម្រាប់ប្រទេសកម្ពុជា) ដែលបានដាក់ ឲ្យសាកល្បងដំបូងនៅក្នុងឆ្នាំសិក្សា ១៩៩៦-១៩៩៧ (MoEYS, 1999)។ មុនពេលបោះពុម្ពស៊េរីសៀវភៅ English for Cambodia (EFC) មានសៀវភៅជាច្រើនដែលត្រូវបានយកមកប្រើមានដូចជា៖ Headway, Streamline និង English for Today ជាដើម។ ក្រោយមកមានគម្រោងជាច្រើនត្រូវបានរៀបចំឡើងដើម្បីចងក្រង និងរៀបចំសៀវភៅភាសាអង់គ្លេសឲ្យសមស្របនឹងប្រទេសកម្ពុជា គឺស៊េរីសៀវភៅ English for Cambodia ដែលត្រូវបានបោះពុម្ពជា ៦ កម្រិតសម្រាប់ឆ្នាំសិក្សានីមួយៗដែលត្រូវបានកំណត់តាមលំដាប់រួមមាន៖ EFC Book 1, 1996; EFC Book 2, 1997; EFC Book 3, 1998; EFC Book 4, 1999; EFC Book 5, 2000 និង EFC Book 6, 2001 (Vira, 2002)។

ថ្មីៗនេះតាមរយៈសេចក្តីណែនាំស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សារបស់ក្រសួងអប់រំ ចុះថ្ងៃទី ៦ តុលា ឆ្នាំ២០១៧។ ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណោះទូទៅ ពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឲ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេស សម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ក្នុងគោលបំណងបង្កើនរយៈពេលសិក្សាភាសាបរទេសនៅតាមសាលាឲ្យបានគ្រប់កម្រិតដើម្បីពង្រឹង និងបង្កើនសម្ថភាពសិស្សានុសិស្សផ្នែកភាសាអង់គ្លេសឲ្យកាន់តែមានសក្តានុពលគឺ ៣ កម្រិតនៅបឋមសិក្សា ៣ កម្រិតនៅអនុវិទ្យាល័យ និង ៣ កម្រិតទៀតនៅវិទ្យាល័យ។

ទោះបីជាមុខវិជ្ជាភាសាអង់គ្លេសបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាតាំងពីឆ្នាំ ១៩៨៩ (Vira,2002) មកក៏ដោយ ក៏មិនទាន់មានឃើញការសិក្សាណាមួយលើ យុទ្ធសាស្រ្តក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាបឋមភូមិ ឬទុតិយភូមិឡើយ។ ហេតុនេះហើយនៅឆ្នាំសិក្សានេះ អ្នកសិក្សានឹងធ្វើការសិក្សាស្វែងយល់ពីយុទ្ធសាស្រ្តក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម ដោយពិនិត្យ និងប្រៀបធៀបភេទ តំបន់ និងផ្នែកវិទ្យាសាស្រ្តពិត និងវិទ្យាសាស្រ្តសង្គម។ បន្ថែមពីនេះទៀតអ្នកសិក្សាក៏នឹងខិតខំរកឲ្យនូវបញ្ហា

ប្រឈមនានាក្នុងការបង្រៀន និងរៀន ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្នផងដែរ។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សានេះគឺដើម្បីពិពណ៌នាអំពីយុទ្ធសាស្ត្រ និងរកឲ្យឃើញនូវអំពីរបៀបដែលសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេស។ ការសិក្សានេះមានគោលបំណងដូចខាងក្រោមៈ

- ស្វែងយល់ពីយុទ្ធសាស្ត្ររបស់សិស្សដែលប្រើក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេស។
- សិក្សាប្រៀបធៀបការប្រើយុទ្ធសាស្ត្ររៀនវាក្យភាសាអង់គ្លេសរបស់សិស្សតាមបណ្តុំ (វិទ្យាសាស្ត្រពិត និងសង្គម) និងភេទ។

## ១.៤- សំណួរស្រាវជ្រាវ

ការសិក្សាបច្ចុប្បន្ននេះពិនិត្យលើការប្រើប្រាស់យុទ្ធសាស្ត្រនៃការរៀនវាក្យសព្ទរបស់សិស្ស នៅកម្រិតមធ្យមសិក្សាវិទ្យាល័យ។ ការសិក្សាពីរបៀបរៀនសូត្រភាសាបរទេស ក៏ដូចជាភាសាអង់គ្លេសរបស់ពួកគេដើម្បីងាយស្រួល ក្នុងការជួយគេឲ្យចាប់អារម្មណ៍ក្នុងការសិក្សាពីរបៀបប្រើយុទ្ធសាស្ត្រការរៀនវាក្យសព្ទប្រកបដោយជោគជ័យ។ ប្រធានបទនេះត្រូវបានទាក់ទងដោយមានជំនួយនៃសំណួរស្រាវជ្រាវចំនួនពីរនឹងត្រូវពិភាក្សាលម្អិតនៅកថាខណ្ឌខាងក្រោម។

សំណួរស្រាវជ្រាវនៃការសិក្សានេះមានដូចខាងក្រោមៈ

១-តើយុទ្ធសាស្ត្រសិក្សាវាក្យសព្ទអ្វីដែលសិស្សប្រើ?

២-តើមានការប្រើប្រាស់យុទ្ធសាស្ត្រសិក្សាវាក្យសព្ទខុសគ្នារវាងសិស្សរៀនបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម និងសិស្សដែលមានភេទខុសគ្នាឬទេ?

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

មុខវិជ្ជាភាសាអង់គ្លេស គឺជាមុខវិជ្ជាសំខាន់មួយក្នុងចំណោមមុខវិជ្ជាដទៃទៀតដែលក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ និងធ្វើការសិក្សាពីលទ្ធភាពដើម្បីដាក់បញ្ចូលជាមុខវិជ្ជាកាតព្វកិច្ចទាំងនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ការសិក្សានេះនឹងធ្វើឲ្យយើងដឹងនូវៈ

១- ការប្រើយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទរបស់សិស្ស

២- រកឲ្យឃើញនូវភាពខុសគ្នារវាងការរៀនវាក្យសព្ទរបស់សិស្សដែលមានភេទខុសគ្នា

៣- រកឲ្យឃើញនូវភាពខុសគ្នារវាងការរៀនវាក្យសព្ទរបស់សិស្សដែលរៀនបណ្តុំមុខវិជ្ជាផ្សេងគ្នា (វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)។

ការដឹងពីយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សច្បាស់លាស់ និងរកឃើញនូវបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការរៀនភាសាអង់គ្លេសរបស់សិស្សនឹងអាចជួយឲ្យគ្រូបង្រៀនភាសាអង់គ្លេស និងអ្នកពាក់

ព័ន្ធយល់ពីតម្រូវការកាន់តែច្បាស់ និងជួយសិស្សឲ្យទទួលបាននូវចំណេះដឹងភាសាអង់គ្លេសបានប្រសើរឡើងសម្រាប់ជាស្ពានឆ្ពោះទៅកាន់ថ្នាក់ឧត្តមសិក្សា។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១- វិសាលភាពនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម" ដោយបង្ហាញអំពីរបៀបនៃការរៀនវាក្យស័ព្ទរបស់សិស្សកន្លងមក។

### ១.៦.២- ដែនកំណត់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើទៅលើវិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដោយជ្រើសរើស យកថ្នាក់ទី១២ ចំនួន ១០ថ្នាក់ ( ថ្នាក់វិទ្យាសាស្ត្រចំនួន ៥ថ្នាក់ និងថ្នាក់វិទ្យាសាស្ត្រសង្គមចំនួន ៥ថ្នាក់)។

## ១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូ ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម ។

**ជំពូកទី៤៖** លទ្ធផលការស្រាវជ្រាវ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីកឲ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន ការពិភាក្សា និងអនុសាសន៍ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែក ធ្វើឲ្យស្ថានភាពបង្រៀន និងរៀនប្រសើរឡើងថែមទៀត។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះអ្នកសិក្សាផ្តោតខ្លាំងទៅលើ និយមន័យពាក្យគន្លឹះដែលទាក់ទងទៅនឹងយុទ្ធសាស្រ្តក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ការរៀនវាក្យសព្ទរបស់សិស្ស សារៈសំខាន់នៃការរៀនវាក្យសព្ទ និងការប្រើយុទ្ធសាស្រ្តរៀនវាក្យសព្ទ។ ពាក្យគន្លឹះសំខាន់ៗដែលអ្នកសិក្សានឹងយកមកពន្យល់បកស្រាយនោះរួមមាន៖ យុទ្ធសាស្រ្ត និងវាក្យសព្ទ ។

## ២.១- និយមន័យ

### ២.១.១- យុទ្ធសាស្រ្ត

យុទ្ធសាស្រ្ត គឺសំដៅលើការរៀបចំផែនការក្នុងការធ្វើអ្វីមួយ។ ម៉្យាងវិញទៀតយុទ្ធសាស្រ្ត គឺជាផែនការ ប្លង់រចនា ឬគំនិតដែលត្រូវបានប្រើដើម្បីសម្រេចគោលដៅជាក់លាក់មួយ។ យុទ្ធសាស្រ្តមួយអាចបត់បែនបាន និងបើកចំហសម្រាប់ការសម្របខ្លួន និងផ្លាស់ប្តូរនៅពេលចាំបាច់។ យុទ្ធសាស្រ្តមួយគឺមានប្រយោជន៍បំផុតនៅពេលភាពច្នៃប្រឌិត ការសហការ និងការច្នៃប្រឌិតមានសារសំខាន់បំផុត។ យុទ្ធសាស្រ្តមួយអនុញ្ញាតឲ្យមានលំហូរធម្មជាតិនៃការគិត និងសន្ទុះជាបន្តដែលបង្កើតរហូតទាល់តែជោគជ័យ។តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត (១៩៨៦) យុទ្ធសាស្រ្ត គឺជាក្បួនចម្បាំង ឬក្បួនសម្រាប់ច្បាំង។ នេះមានន័យថា ជាសំណុំនៃផែនការដើម្បីរៀបចំគម្រោងក្នុងគោលបំណងអ្វីមួយ ដើម្បីសម្រេចទិសដៅ។ ឧទាហរណ៍៖ បង្កើតយុទ្ធសាស្រ្តឡើង ក្នុងគោលបំណងដើម្បីអនុវត្តន៍ឲ្យទទួលបានភាពជោគជ័យ។

### ២.១.២- វាក្យសព្ទ

យោងតាមវចនានុក្រមរបស់សម្តេចជួនណាតវាក្យសព្ទ គឺមកពីពាក្យ វាក្យ + សព្ទ ។ វាក្យ មានន័យថា ពាក្យ, សម្តី, វោហារ រីឯសព្ទ មានន័យថាជា សូរ, សំឡេង, សំនៀង។ ដូចនេះវាក្យសព្ទមានន័យថាជាប្រជុំពាក្យសម្រាប់ប្រើក្នុងភាសានីមួយៗ (ដកស្រង់ចេញពីវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត)

វាក្យសព្ទ គឺជាបណ្តុំនៃពាក្យស្រដៀងគ្នានៅក្នុងភាសារបស់មនុស្ស។ ជាទូទៅវាក្យសព្ទបានកើនឡើងតាមអាយុដែលជាឧបករណ៍ដ៏មានប្រយោជន៍ និងសារៈសំខាន់សម្រាប់ការទំនាក់ទំនង និងការទទួលបានចំនេះដឹង។ ការទទួលបានវាក្យសព្ទទូលំទូលាយ គឺជាការប្រគួតប្រជែងធំមួយក្នុងការរៀនភាសាបរទេស។

វាក្យសព្ទគឺជាចំនួនពាក្យសរុបនៅក្នុងភាសា។ ពាក្យទាំងអស់ដែលមនុស្សចេះ ឬប្រើក្នុងសៀវភៅ និងមុខវិជ្ជាផ្សេងៗ។ល។ បញ្ជីពាក្យដែលមានអត្ថន័យរបស់ពួកគេ ជាពិសេសអត្ថន័យដែលភ្ជាប់ជាមួយសៀវភៅសិក្សា (Hornby, 1995: 1331) ។ និយមន័យទាំងនោះបង្ហាញថាវាក្យសព្ទ គឺជាធាតុដំបូងដែលអ្នកសិក្សាភាសាអង់គ្លេស ឬក៏ភាសាបរទេសដទៃទៀតគួរតែរៀនដើម្បីឲ្យចេះស្ទាត់ជំនាញភាសា។

វាក្យសព្ទសំដៅលើពាក្យដែលត្រូវបានប្រើក្នុងការនិយាយ និងបោះពុម្ពដើម្បីទំនាក់ទំនង។ វាក្យសព្ទអាចត្រូវបានបែងចែកជាពីរប្រភេទៈ វាក្យសព្ទ ផ្ទាល់មាត់ ជាពាក្យដែលប្រើក្នុងការនិយាយ ឬការស្តាប់។ និងវាក្យសព្ទដែលប្រើក្នុងការអាន ការសរសេរ ឬការបោះពុម្ព (National Institute for Literacy 14) ។

សរុបមកការស្គាល់ពាក្យ វាក្យសព្ទ មានន័យថាដឹងពីអត្ថន័យ ការប្រើពាក្យ ការបង្កើតពាក្យ និងវេយ្យាករណ៍, Harmer (1991: 158)។

## ២.២- ការរៀនវាក្យសព្ទភាសាអង់គ្លេស

វាក្យសព្ទ គឺជាផ្នែកសំខាន់នៃការរៀនសូត្រ និងការបង្រៀនភាសា។ ដោយហេតុផលនេះការស្រាវជ្រាវវាក្យសព្ទបានកើនឡើងក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយ។ Laufer (1986) បានចង្អុលបង្ហាញថាការទទួលបានភាសាមិនអាចកើតឡើងបានទេបើគ្មានការរៀនសូត្រ និងស្ទាត់ជំនាញលើពាក្យ ឬវាក្យសព្ទ។ អ្នកសិក្សា និងអ្នកស្រាវជ្រាវជាច្រើនបានព្យាយាមកំណត់ និងបែងចែកប្រភេទផ្សេងៗគ្នានៃយុទ្ធសាស្រ្តរៀនវាក្យសព្ទ (O‟Malley & Chamot, 1990; Oxford, 1990; Schmitt, 1997, 2000, Takač, 2008). O‟Malley and Chamot (1990), កំណត់និយមន័យនៃការរៀនសូត្រវាក្យសព្ទ ជា" គំនិត ឬអាកប្បកិរិយាពិសេសដែលបុគ្គលម្នាក់ៗប្រើដើម្បីស្វែងយល់រៀន ឬរក្សាទុកព័ត៌មាន (ទំព័រ ១) ខណៈដែល Takač (2008) សំដៅទៅលើពួកគេ " យុទ្ធសាស្រ្តជាក់លាក់ដែលត្រូវបានប្រើប្រាស់ក្នុងការងារដាច់ឆ្ងាយនៃវាក្យសព្ទរៀនជាភាសាគោលដៅ" (ទំព័រ ៥២)។

ក្នុងការរៀនភាសា ការប្រើយុទ្ធសាស្រ្តក្នុងការរៀនសូត្រសម្រាប់ការបង្កើននូវវាក្យសព្ទគឺមានសារៈសំខាន់ខ្លាំងណាស់ ហើយអ្នកស្រាវជ្រាវបានកំណត់ យុទ្ធសាស្រ្តនៃសិក្សាវាក្យសព្ទជាច្រើនដែលអាចត្រូវបានបង្រៀនដល់សិស្ស។ យុទ្ធសាស្រ្តសិក្សាភាសាត្រូវបានកំណត់ជាសកម្មភាពដែលត្រូវបានប្រើដោយអ្នកសិក្សា ដើម្បីឲ្យការរៀនសូត្ររបស់ពួកគេកាន់តែងាយស្រួល និងមានប្រសិទ្ធភាពថែមទៀត ហើយអាចត្រូវបានប្រើ ឬក៏ផ្លាស់ប្តូរទៅស្ថានភាពផ្សេងទៀត (Oxford, 1990) ។ យុទ្ធសាស្រ្តទាំងនេះគឺជាឧបករណ៍សិក្សាសម្រាប់សិស្សដែលពួកគេអាចប្រើប្រាស់ដោយខ្លួនឯងដើម្បីទទួលបានវាក្យសព្ទ និងធ្វើឲ្យពួកគេក្លាយជាអ្នកទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ពួកគេផ្ទាល់ (Nation, 2001) ។ ជាមួយនឹងជំនាញ និងចំណេះដឹងនៃយុទ្ធសាស្រ្តរៀនសូត្រអ្នកសិក្សាអាចរៀនវាក្យសព្ទថ្មីដោយគ្មានវត្តមានរបស់គ្រូបង្រៀន ។ នេះអាចនិយាយបានថាពួកគេអាចរៀនពាក្យថ្មីដោយខ្លួនឯងនៅពេលណាដែលគេឆ្លៀតបាន។ អ្នកសិក្សាអាចប្រើយុទ្ធសាស្រ្តរៀនសូត្រផ្សេងៗគ្នា ហើយពួកគេគួរតែត្រូវបានបង្រៀនពីរបៀបប្រើយុទ្ធសាស្រ្តក្នុងការរៀន។

យុទ្ធសាស្រ្តរៀនភាសាជាសកម្មភាពជាក់លាក់អាកប្បកិរិយាជំហាន ឬបច្ចេកទេសដែលអាចជួយសម្រួលដល់ការធ្វើឲ្យស្ទាត់ជំនាញការរក្សាទុកការទាយក ឬការប្រើប្រាស់ភាសាភាសាថ្មីដែលមានជំនាញក្នុងការអភិវឌ្ឍជំនាញ ភាសាបរទេសរបស់ពួកគេ (Oxford 1992: 124)។ យុទ្ធសាស្រ្តទាំងនេះគឺជា

ឧបករណ៍សម្រាប់ការចូលរួមដោយខ្លួនឯងដែលចាំបាច់សម្រាប់ការអភិវឌ្ឍសមត្ថភាពទំនាក់ទំនង (Oxford, 1992: 124) ។

ដោយឡែក Green and Oxford (1995) បានមើលពីការប្រើយុទ្ធសាស្ត្ររៀនភាសាបរទេសតាមភេទរបស់សិស្សក៏បានរកឃើញទំនាក់ទំនងសំខាន់រវាងការប្រើប្រាស់យុទ្ធសាស្ត្រ និងភេទ។ ជាថ្មីម្តងទៀត ការរកឃើញរបស់ពួកគេបានបង្ហាញថាស្ត្រីបានប្រើយុទ្ធសាស្ត្ររៀនច្រើនជាងបុរស។ Omaar (2016) បានធ្វើការស្រាវជ្រាវលើនិស្សិតសាកលវិទ្យាល័យ Tuareg នៃប្រទេសលីប៊ីទាក់ទងនឹងភាពខុសគ្នារបស់និស្សិតប្រុស និងស្រីក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទ។ ក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទទូទៅ Omaar (2016) រកឃើញថាមិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងនិស្សិតប្រុស និងនិស្សិតស្រីនោះទេ។ ទាក់ទងនឹងភេទនេះដែរ Lee & Oxford (2008) បានរកឃើញថាភេទមិនប៉ះពាល់ដល់ការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទទេ ហើយបានផ្តល់យោបល់ថាការលើកកម្ពស់យុទ្ធសាស្ត្រការរៀនដោយផ្អែកលើភាពខុសគ្នាធំៗ មិនមែនជាគោលដៅជាក់ស្តែងទេ។

តាមធម្មតាអ្នកសិក្សាមានពីរប្រភេទគឺអ្នករៀនពូកែ និងអ្នករៀនខ្សោយ។ អ្នកសិក្សាដែលទទួលបានជោគជ័យគឺជាអ្នកដែលដឹងពីដំណើរការនៃការរៀនសូត្រ ដឹងពីសារៈសំខាន់នៃការរៀនពាក្យតាមបរិបទ និងដឹងពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងវាក្យសព្ទ ភាសាបរទេសថ្មី និងវាក្យសព្ទរៀនពីមុន។ ក្រៅពីវចនានុក្រម ពួកគេក៏ពឹងផ្អែកលើអ្នកសិក្សាដទៃទៀត ប្រភពព័ត៌មាននៃការសិក្សាវាក្យសព្ទផងដែរ។ ម៉្យាងវិញទៀតអ្នករៀនខ្សោយប្រើយុទ្ធសាស្ត្រច្រើនប៉ុន្តែពួកគេប្រើវាមិនត្រឹមត្រូវ (Pavicic, 2008: 37) ។ គាត់ក៏បានរាយការណ៍ផងដែរថា "អ្នកសិក្សាខ្សោយជាទូទៅប្រើយុទ្ធសាស្ត្ររៀនតិចជាងអ្នករៀនពូកែ ហើយពួកគេមិនដឹងពីរបៀបរៀនវាក្យសព្ទ ឬវិធីភ្ជាប់វាជាមួយចំណេះដឹងដែលទទួលបានហើយក៏មិនបានអនុវត្តន៍សកម្មភាពដែរ"។ ហេតុដូច្នេះហើយពួកគេមិនមានវឌ្ឍនភាពជាក់ស្តែងនៅក្នុងភាសាគោលដៅនោះទេ។ កត្តាចិត្តសាស្ត្រផ្សេងទៀតដូចជាការស្ទាក់ស្ទើរ ការអៀនខ្មាស់ ការមិនយកចិត្តទុកដាក់ខ្លួនឯង។ ល។ ជះឥទ្ធិពលដល់ការអភិវឌ្ឍរបស់ពួកគេ។ "អ្នកសិក្សាភាសាបរទេសដែលទទួលបានជោគជ័យគឺជាអ្នកប្រមូលផ្តុំពាក្យហើយចូលចិត្តវាស់ស្ទង់ភាពជោគជ័យរបស់ខ្លួនដោយចំនួនពាក្យដែលគេដឹង" (Meara, 2009: 51) ។

## ២.៣- សារៈសំខាន់នៃការរៀនវាក្យសព្ទ

វាក្យសព្ទ គឺជាចំណុចសំខាន់នៃការបង្រៀនភាសាអង់គ្លេសដោយសារតែបើមិនចេះពាក្យគ្រប់គ្រាន់សិស្សមិនអាចយល់ពីអ្នកដទៃ ឬបង្ហាញគំនិតផ្ទាល់ខ្លួនរបស់ពួកគេបានឡើយ។ David Wilkins (1972) បានសរសេរថា "បើមិនមានវេយ្យាករណ៍គេអាចយល់បានខ្លះ តែបើគ្មានពាក្យគេនឹងមិនយល់អ្វីទាំងអស់" David Wilkins (ទំព័រ 111-112) ។ ចំណុចនេះឆ្លុះបញ្ចាំងពីបទពិសោធន៍ជាមួយភាសាផ្សេងៗ។ សូម្បីតែមិនមានវេយ្យាករណ៍ដោយមានពាក្យ និងឃ្លាមួយចំនួនគេក៏អាចទំនាក់ទំនងបានផងដែ។ Lewis (1993) បានជជែកវែកញែកបន្តទៀតថា "ពាក្យគឺជាស្នូល ឬបេះដូងនៃភាសា"។ ជាពិសេសនៅពេលដែលសិស្សមាន

ការរីកចម្រើន និងអាចបញ្ចេញមតិកាន់តែប្រសើរឡើងជាភាសាអង់គ្លេសវាមានសារៈសំខាន់សម្រាប់ពួកគេដើម្បីទទួលបានចំណេះដឹងវាក្យសព្ទកាន់តែច្រើន និងបង្កើតយុទ្ធសាស្ត្រសិក្សាវាក្យសព្ទផ្ទាល់ខ្លួនរបស់ពួកគេផ្ទាល់។

ចំណេះដឹងវាក្យសព្ទ ជារឿយៗត្រូវបានគេមើលឃើញថាជាឧបករណ៍ដ៏សំខាន់សម្រាប់អ្នកសិក្សាភាសាភាសាបរទេស ពីព្រោះវាក្យសព្ទមានកំណត់អាចរារាំងក្នុងការប្រាស្រ័យទាក់ទងប្រកបដោយជោគជ័យ។ ដោយបញ្ជាក់ពីសារៈសំខាន់នៃការទទួលបានវាក្យសព្ទ លោក Schmitt (2000) បានសង្កត់ធ្ងន់ថា "ចំណេះដឹងខាងវាក្យសព្ទគឺសំខាន់សម្រាប់សមត្ថភាពទំនាក់ទំនង និងការការយល់ដឹងនូវភាសាបរទេស" (ទំព័រ ៥៥)។

Nation (2001) ពិពណ៌នាបន្ថែមទៀតពីទំនាក់ទំនងរវាងចំណេះដឹងវាក្យសព្ទ និងការប្រើប្រាស់ភាសាជាការបន្ថែមៈចំណេះដឹងវាក្យសព្ទអាចជួយឲ្យការប្រើប្រាស់ភាសា ហើយផ្ទុយទៅវិញការប្រើប្រាស់ភាសានាំឲ្យមានការកើនឡើងនូវចំណេះដឹងវាក្យសព្ទ។ សារៈសំខាន់នៃវាក្យសព្ទត្រូវបានបង្ហាញនៅក្នុង និងក្រៅសាលា។ នៅក្នុងថ្នាក់រៀនសិស្សពូកែមានវាក្យសព្ទគ្រប់គ្រាន់បំផុតសម្រាប់ប្រាស្រ័យទាក់ទង។

អ្នកស្រាវជ្រាវដូចជា Laufer and Nation (1999), Maximo (2000), Read (2000), Gu (2003), Marion (2008) and Nation (2011) និងអ្នកផ្សេងទៀតបានដឹងថាការទទួលបានវាក្យសព្ទគឺចាំបាច់សម្រាប់ការប្រើប្រាស់ភាសាបរទេសដែលទទួលបានជោគជ័យ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអត្ថបទនិយាយ និងសរសេរពេញលេញ។ ការរៀនវាក្យសព្ទភាសាអង់គ្លេស ដើរតួយ៉ាងសំខាន់ក្នុងជំនាញភាសាទាំងអស់ ឧទាហរណ៍ៈការស្តាប់ ការនិយាយ ការអាន និងការសរសេរ (Nation,2011)។ Rivers and Nunan (1991) អះអាងបន្ថែមទៀតថាការទទួលបានវាក្យសព្ទគ្រប់គ្រាន់គឺចាំបាច់សម្រាប់ការប្រើប្រាស់ភាសាបរទេសដែលទទួលបានជោគជ័យ ពីព្រោះបើគ្មានវាក្យសព្ទទូលំទូលាយទេយើងនឹងមិនអាចប្រើនូវសំណង់ និងមុខងារប្រយោគដែលយើងបានរៀនសម្រាប់ការប្រាស្រ័យទាក់ទងយល់បាននោះទេ។

សិស្សជាញឹកញាប់យល់ពីសារៈសំខាន់នៃវាក្យសព្ទទៅនឹងការសិក្សាភាសារបស់ពួកគេ។ ដូចលោក Schmitt (ឆ្នាំ 2010) បានកត់សម្គាល់ថា "អ្នកសិក្សាជាច្រើនយកវចនានុក្រមតាមខ្លួន មិនមែនសៀវភៅវេយ្យាករណ៍ទេ" (ទំព័រ ៤) ។ ការបង្រៀនពាក្យជួយឲ្យសិស្សយល់ និងប្រាស្រ័យទាក់ទងជាមួយអ្នកដទៃជាភាសាអង់គ្លេសបាន។ Voltaire បាននិយាយយ៉ាងច្បាស់ថា "ភាសាពិបាកសរសេរណាស់" ។ ហើយលោកជឿថាសិស្សភាសាអង់គ្លេសនឹងយល់ស្រប តែការរៀនវាក្យសព្ទក៏ជួយសិស្សឲ្យចេះប្រើភាសាអង់គ្លេសសម្រាប់គោលបំណងរបស់ពួកគេផងដែរ។

ម្យ៉ាងវិញទៀត វាក្យសព្ទត្រូវបានគេទទួលស្គាល់ថាជាប្រភពបញ្ហាធំបំផុតរបស់អ្នកសិក្សាភាសាបរទេស (Meara, 1980)។ ការកត់សម្គាល់នេះអាចឆ្លុះបញ្ចាំងឲ្យឃើញថាការបន្តនៃប្រព័ន្ធវាក្យសព្ទត្រូវបានគេយល់ថាជាបុព្វហេតុនៃការលំបាកដោយអ្នកសិក្សា។ ហេតុផលមួយទៀតដែលអាចទៅរួចនោះគឺថាមិនដូចការរៀបសំណង់ប្រយោគតាមវេយ្យាករណ៍ និងសូរស័ព្ទទេ វាក្យសព្ទ មិនមានច្បាប់ដែលអ្នកសិក្សានឹងធ្វើតាមដើម្បីទទួលបាន និងអភិវឌ្ឍន៍ចំណេះដឹងរបស់ពួកគេនោះទេ។ ជាងនេះទៀតវាមិនច្បាស់ទេនៅក្នុងវាក្យសព្ទភាសាបរទេសដែលរៀនពីអ្វីដែលច្បាប់ត្រូវបានអនុវត្តន៍ ឬតើធាតុវាក្យសព្ទណាមួយគួរតែត្រូវបានរៀនជាមុន។ Oxford (1990) ក៏បានអះអាងផងដែរថាវាក្យសព្ទគឺ "មានទំហំច្រើនបំផុត ហើយសមាសធាតុដែលមិនអាចគ្រប់គ្រងបានក្នុងការរៀនសូត្រភាសាណាមួយ មិនថាភាសាបរទេស ឬភាសាកំណើតដោយសារអត្ថន័យខុសគ្នារាប់ពាន់។ ទោះបីជាមានការលំបាកទាំងនេះដែលអ្នកសិក្សាភាសាជួបប្រទះនឹងការរៀនវាក្យសព្ទភាសាបរទេសក៏ដោយ ក៏ពួកគេនៅតែត្រូវដោះស្រាយវានៅក្នុងការប្រឡងរបស់ពួកគេដែរថាវាក្យសព្ទ គឺជាផ្នែកមួយនៃសមាសធាតុភាសាដែលត្រូវបានវាស់នៅក្នុងការធ្វើតេស្តភាសា (Schmitt, 1999, 189)។ លើសពីនេះទៅទៀតអ្នកសិក្សាជាច្រើនយល់ឃើញថាការទទួលបានភាសាបរទេស គឺជាបញ្ហាសំខាន់នៃការរៀនសូត្រវាក្យសព្ទ ហើយដូច្នេះពួកគេចំណាយពេលវេលាយ៉ាងច្រើនដើម្បីទន្ទេញចាំបញ្ជីពាក្យ ហើយពឹងផ្អែកលើវចនានុក្រមពីរភាសារបស់ពួកគេជាធនធានទំនាក់ទំនងមូលដ្ឋាន។ ជាលទ្ធផលគ្រូភាសា និងអ្នកអនុវត្តភាសាវិទូជាទូទៅទទួលស្គាល់សារៈសំខាន់នៃការរៀនវាក្យសព្ទ ហើយកំពុងស្វែងរកវិធីនៃការផ្សព្វផ្សាយវាឲ្យកាន់តែមានប្រសិទ្ធភាព។ ការសិក្សាស្រាវជ្រាវខ្លះយកទម្រង់នៃការស៊ើបអង្កេតនៃយុទ្ធសាស្ត្រដែលអ្នកសិក្សាប្រើជាពិសេសសម្រាប់វាក្យសព្ទដែលជាការយកចិត្តទុកដាក់របស់យើង។

## ២.៤- ការប្រើយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទ

និយមន័យទូទៅនៃយុទ្ធសាស្ត្ររៀនវាក្យសព្ទ ត្រូវបានផ្តល់ដោយ Cameron (2001: 92) ដែលបាននិយាយថាយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទគឺជា "សកម្មភាពដែលអ្នករៀនប្រើដើម្បីជួយខ្លួនឯងឲ្យយល់ និងចងចាំវាក្យសព្ទ" ។ Brown and Payne (1994, ដកស្រង់ដោយ Hatch & Brown, ឆ្នាំ 1995: 373) បានកំណត់ជំហានប្រាំដែលពាក់ព័ន្ធនឹងការរៀនវាក្យសព្ទ: ១) មានប្រភពសម្រាប់ជួបនឹងពាក្យថ្មី ២) ទទួលបានរូបភាពច្បាស់លាស់ទាំងរូបភាព ឬសំឡេង ឬទាំងពីរនៃទម្រង់ពាក្យថ្មី ៣) រៀនអត្ថន័យនៃពាក្យ ៤) បង្កើតការចងចាំដ៏រឹងមាំរវាងទម្រង់ និងអត្ថន័យនៃពាក្យហើយ ៥) ការប្រើពាក្យ។

ជារើយៗយុទ្ធសាស្ត្រទាំងអស់សម្រាប់ការរៀនវាក្យសព្ទភាសាបរទេសមានកម្រិតជាក់លាក់មួយទាក់ទងទៅនឹងជំហានទាំងប្រាំនេះ (Fan, 2003: 223)។

ជាជាងត្រូវបានប្រើជាលក្ខណៈបុគ្គលយុទ្ធសាស្ត្រសិក្សាវាក្យសព្ទច្រើនត្រូវបានប្រើជាទៀងទាត់។ វាមានន័យថាការគ្រប់គ្រងសកម្មនៃការប្រើយុទ្ធសាស្ត្រគឺមានសារៈសំខាន់។ ការរៀបចំយុទ្ធសាស្ត្រទូទៅនៃ

យុទ្ធសាស្ត្រដែលបានពិភាក្សានៅក្នុងផ្នែកជាបន្តបន្ទាប់ខាងក្រោមគឺផ្អែកលើ Ming Wei (2007) ពោលគឺជាប្រភេទធំៗនៃយុទ្ធសាស្ត្រដែលបានមកពីការបែងចែកវា។ ចំណាត់ថ្នាក់នេះ គឺមិនល្អឥតខ្ចោះទេ (Fan 2003: 223) ជឿជាក់ថាការដាក់ចំណាត់ថ្នាក់មិនល្អឥតខ្ចោះទេហើយយុទ្ធសាស្ត្របុគ្គលនីមួយៗអាចធ្លាក់ចូលទៅក្នុងប្រភេទមួយ ឬផ្សេងទៀត។ ឧទាហរណ៍វាពិបាកក្នុងការកំណត់ការកត់សម្គាល់ជាយុទ្ធសាស្ត្រគ្រប់គ្រង ឬប្រភេទប្រភព។

យុទ្ធសាស្ត្រសិក្សាវាក្យសព្ទត្រូវបានបង្កើតឡើងដើម្បីជួយសម្របសម្រួលដល់អ្នកសិក្សា និងបង្កើនការរៀនវាក្យសព្ទរបស់ពួកគេដើម្បីសម្រេចបាននូវគោលដៅ។ Schmitt (2000) បានពន្យល់ថា យុទ្ធសាស្ត្រសិក្សាវាក្យសព្ទ អាចផ្តល់អំណាចដល់អ្នកសិក្សា និងទាក់ទាញចំណាប់អារម្មណ៍របស់អ្នកសិក្សាក្នុងការរៀនភាសាក្នុងរបៀបមួយដែលនឹងធ្វើឲ្យប្រសើរឡើងដល់ការអភិវឌ្ឍវាក្យសព្ទរបស់អ្នកសិក្សា។ Schmitt (1997) ក៏បានលើកឡើងផងដែរថានៅក្នុងដំណើរការវាក្យសព្ទ ដោយសង្កត់ធ្ងន់លើការយល់ដឹងពីភាសា។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រសិក្សាវាក្យសព្ទ មានសារៈសំខាន់ក្នុងការរៀនភាសាបរទេសដើម្បីបង្កើននូវតម្រូវការ។ យោងទៅតាម Takac (2008) យុទ្ធសាស្ត្រសិក្សាវាក្យសព្ទ គឺជាយុទ្ធសាស្ត្រជាក់លាក់ក្នុងការប្រើប្រាស់សកម្មភាពរៀនវាក្យសព្ទនៅក្នុងគោលដៅមួយនៃការសិក្សាភាសា។ លើសពីនេះទៅទៀត ការប្រើយុទ្ធសាស្ត្រសិក្សាវាក្យសព្ទ គឺជាវិធីសាស្ត្រក្នុងការរៀនវាក្យសព្ទដែលជួយសម្រួលការរៀនសូត្រភាសាអង់គ្លេសមានប្រសិទ្ធភាព (Amiryousefi & Ketabi, 2011)។ សម្រាប់ហេតុផលនេះ យុទ្ធសាស្ត្រសិក្សាវាក្យសព្ទ អាចជួយអ្នកសិក្សាស្វែងយល់អត្ថន័យនៃពាក្យនៅក្នុងភាសាគោលដៅដើម្បីពង្រីកចំណេះដឹងវាក្យសព្ទរបស់ពួកគេ (Hulstjin,1993, Morin &Goebel, 2001) ។

បន្ថែមពីនឹងទៀត (Asgari & Mustapha, 2011) កំណត់យុទ្ធសាស្ត្រសិក្សាវាក្យសព្ទជាដំណាក់កាលដែលត្រូវបានអនុវត្តន៍ដោយអ្នករៀននៅពេលរៀនពាក្យថ្មី។ នៅពេលសិស្សានុសិស្សជួបប្រទះភាសាអង់គ្លេសថ្មីនៅក្នុងដំណើរការសិក្សារបស់ពួកគេ, ពួកគេត្រូវចាត់វិធានការដើម្បីយល់ពាក្យទាំងនោះដើម្បីជួយឲ្យពួកគេយល់ពីសម្ភារៈ។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រសិក្សាវាក្យសព្ទមិនត្រឹមតែផ្តោតអារម្មណ៍ទៅលើរបៀបដែលសិស្សរៀនពីវាក្យសព្ទថ្មី ប៉ុន្តែក៏បានផ្តោតទៅលើរបៀបដែលពួកគេរក្សាទុកពាក្យនៅក្នុងការចងចាំរយៈពេលវែងរបស់ពួកគេក៏ដូចជាការប្រើប្រាស់ និងផលិតពាក្យនៅក្នុងបរិបទសមស្របដូចដែលបានថ្លែងដោយ Ruutments (2005) និងត្រូវបានលើកឡើងដោយ Jurcoviæ (ឆ្នាំ 2006)។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមគោលបំណងក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយដៅតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទីតាំងភូមិសាស្ត្រ និងភាគសំណាក ឧបករណ៍ស្រាវជ្រាវ ដំណើរការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១- ប្រជាជន និងភាគសំណាក

### ៣.១.១- ប្រជាជន

កំពង់ចាម គឺជាខេត្តនៃប្រទេសកម្ពុជាដែលស្ថិតនៅវាលទំនាបកណ្តាលនៃទន្លេមេគង្គ។ វាមានព្រំប្រទល់ជាប់នឹងខេត្តកំពង់ឆ្នាំងនៅខាងលិច កំពង់ធំ និង ក្រចេះនៅខាងជើង ត្បូងឃ្មុំនៅខាងកើត និង ព្រៃវែង និង កណ្តាលនៅខាងត្បូង។ យោងតាមស្ថិតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ខេត្តកំពង់ចាមមានប្រជាជនសរុបចំនួន ៨៩៥,៧៦៣នាក់ (ប្រុសចំនួន ៤២៨,៤៨១នាក់ និងស្រីចំនួន ៤៦៧,២៨២នាក់) និងមានចំនួន ២១៥,៩២៣គ្រួសារ ។

### ៣.១.២- ភាគសំណាក

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ មកពីវិទ្យាល័យ ចំនួន ០៥ ដែលស្ថិតក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ក្នុងចំណោមសិស្សថ្នាក់ទី១២ សរុបចំនួន ៦,០៤៩ នាក់ ស្រីចំនួន ៣,៣៣៨នាក់( ថ្នាក់វិទ្យាសាស្ត្រចំនួន ៣,១៣៨ និងស្រី ១,៨៥០នាក់) និង(ថ្នាក់វិទ្យាសាស្ត្រសង្គមចំនួន ២៩១១ ស្រីចំនួន ១,៤៨៨ នាក់ ក្នុងខេត្តកំពង់ចាម (តារាងសំណើរមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៩)។

**តារាងទី១៖ ភេទ បណ្តុំសិក្សា សមត្ថភាពភាសាអង់គ្លេសនៅតាមវិទ្យាល័យទាំង ៥**

| ប្រភេទ | វិទ្យាល័យ | | | | |
|---|---|---|---|---|---|
| | វិ.សអគជហស. បាធាយ (៦៣) | វិ.ហាណហ.ព្រៃញា(៨៨) | វិ.សតហស. សណ្តោក (៨៨) | វិ.ហាស ជើងឆ្នុក (៦៤) | វិ.ហាស សង្កើប (៥២) |
| **ភេទ** | | | | | |
| ប្រុស | ២១(%) | ២៩(%) | ៥១(%) | ៣៧(%) | ២៥(%) |
| ស្រី | ៤២(%) | ៥៩(%) | ៣៧(%) | ២៧(%) | ២៧(%) |

| | | | | | |
|---|---|---|---|---|---|
| **បណ្តុំសិក្សា** | | | | | |
| វិទ្យាសាស្ត្រ | ២៩(%) | ៤៣(%) | ២៩(%) | ៣៣(%) | ២២(%) |
| សង្គម | ៣៤(%) | ៤៥(%) | ៥៩(%) | ៣១(%) | ៣០(%) |
| **សមត្ថភាពភាសាអង់គ្លេស** | | | | | |
| សិស្សពូកែ | ១៣(%) | ៨(%) | ១០(%) | ៧(%) | ៥(%) |
| សិស្សខ្សោយ | ៥០(%) | ៨០(%) | ៧៨(%) | ៥៧(%) | ៤៧(%) |

មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយកវិទ្យាល័យទាំងនោះសម្រាប់ធ្វើការស្រាវជ្រាវ ដោយសារសាលារៀនទាំងនោះ ស្ថិតនៅក្នុងតំបន់ផ្សេងៗគ្នា (វិទ្យាល័យចំនួន៣ស្ថិតនៅក្នុងប្រជុំជន និង ២ផ្សេងទៀតស្ថិតនៅតាមជាយស្រុក)។

## ៣.២- ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើ អ្នកស្រាវជ្រាវបានដកស្រង់កម្រងសំណួរជ្រើសរើស ចំនួន ៤០ចំណុច ចែកជា ៤ផ្នែក ចេញមកពីនិក្ខេបបទរបស់ លោក Richard A. LaBontee, Jr (2019) ដែលមាន ៦៩ ចំណុច ចែកចេញជា ៧ផ្នែក។ ***(មើលឧបសម្ព័ន្ធទី ៣)***

ការយកកម្រងសំណួរមកប្រើនេះ អ្នកស្រាវជ្រាវធ្វើការរៀបចំឡើងវិញដើម្បីឲ្យស៊ីនឹងបរិបទប្រទេស កម្ពុជា និងធ្វើការបកប្រែជាភាសាខ្មែរ និងកែសម្រួលក្នុងគោលបំណងឲ្យភាគីពាក់ព័ន្ធងាយយល់ដោយមាន ការចូលរួមពីក្រុមគ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យ ហោ ណាំហុងព្រៃញា ក្រោមការត្រួតពិនិត្យផ្ទាល និងឯកភាពពីលោកគ្រូដឹកនាំ។

ដើម្បីឲ្យការប្រមូលទិន្នន័យមានភាពងាយស្រួល និងបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើត ទម្រង់កម្រងសំណួរស្រាវជ្រាវសម្រាប់សិស្សានុសិស្ស ដែលចែកចេញជាពីរផ្នែកគឺ៖ ព័ត៌មានទូទៅ និងកម្រង សំណួរជ្រើសរើស។

**ផ្នែកទី១៖** អំពីព័ត៌មានទូទៅចែកចេញជា៦ចំណុចគឺ (១)ឈ្មោះខេត្ត (២)ឈ្មោះស្រុក (៣)ឈ្មោះ សាលា (៤) បណ្តុំមុខវិជ្ជា (៥)ថ្នាក់ទី (៦)ភេទ ។

**ផ្នែកទី(២)៖** ជាកម្រងសំណួរជ្រើសរើសដែលមានចំនួន ៤០ និងតម្រូវឲ្យសិស្ស ជ្រើសរើសតាមការ ណែនាំអំពីអ្វីដែលត្រូវនឹងសកម្មភាពរៀនសូត្ររបស់ពួកគេដោយគូសសញ្ញាគ្រីស (✓) លើចំណុចណាមួយ ដែលគេបានធ្វើ និងមិនបានធ្វើទៅតាមកម្រិតនៃសកម្មភាពនីមួយៗពី ១ ដល់ ៥(១ = មិនដែល ២ = មិនសូវ ៣ = ជួនកាល ៤ = ជារើយៗ និង៥ = ជានិច្ចជាកាល)។ ទន្ទឹមនឹងគ្នានេះដែរកម្រិតនៃភាពអាចជឿជាក់បាន (Reliability) យកក្នុងកម្រិត (០.៩៣)។ ***(មើលឧបសម្ព័ន្ធទី ៤)***

ជាមួយគ្នានេះផងដែរ ដើម្បីបង្ហាញពីភាពជឿជាក់ និងអាចយកជាការបានអ្នកស្រាវជ្រាវក៏បានបង្កើតតេស្តជ្រើសរើសមួយដែលមាន ១០ ចំណុចសម្រាប់ឲ្យសិស្សធ្វើការជ្រើសរើសយកចម្លើយត្រឹមត្រូវតែមួយគត់ក្នុងមួយចំណុចៗ។

### ៣.៣- ដំណើរការប្រមូលទិន្នន័យ

បន្ទាប់ពីកម្រងសំណួរមានការឯកភាពពីគ្រូដឹកនាំ និងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ លេខ : ១១៩ វជអ.ផក ចុះថ្ងៃ សុក្រ ១៤ កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៦ នៃវិទ្យាស្ថានជាតិអប់រំឲ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា។ និងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ : ១៨៨៥ អយក.វជអ ចុះថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៩ ស្តីពីការស្នើទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តនានា សុំជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា ***(មើលឧបសម្ព័ន្ធទី ១)***។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាមនេះ ដោយសារតែសាលាគោលដៅយកមកធ្វើការស្រាវជ្រាវទាំងនេះ ស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម តាមរយៈលិខិតឧទ្ទេសនាមលេខ : ៨៧៥/១៩ ឧទន.រប ចុះថ្ងៃ អង្គារ ១០ រោច ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុកគោលដៅនានា ក្នុងខេត្តកំពង់ចាមមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់ ដើម្បីជួបពិភាក្សាជាមួយនាយកសាលាក្នុងគោលបំណងកំណត់កាលបរិច្ឆេទជួបសិស្សដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុន ធ្វើយ៉ាងណាមិនឲ្យប៉ះពាក់ដល់ការបង្រៀន និងការរៀនរបស់សិស្ស ***(មើលឧបសម្ព័ន្ធទី ២)***។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលាអំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សាស្រាវជ្រាវ។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយ គាត់ក៏បានអនុញ្ញាតឲ្យរៀបចំការប្រមូលទិន្នន័យទៅតាមផែនការដែលឯកភាពគ្នា។

មុនការចុះប្រមូលទិន្នន័យផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តកំពង់ចាម ។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរដើម្បីឲ្យដឹងថាអាចយកមកប្រមូលទិន្នន័យជាផ្លូវការបាន ឬមិនបាន។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនេះអ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាល្បងនេះពិតជាទទួលបានផលល្អមែន ព្រោះយើងរកឃើញចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបាន

យោបល់ត្រឡប់ក្នុងការកែលម្អ កម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យ ណែនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅទាំង៥ក្នុងស្រុកបាធាយ។ មុននឹងដាក់ឲ្យសិស្សជ្រើសរើសនូវចំណុចនីមួយៗ អ្នកស្រាវជ្រាវបានធ្វើការណែនាំពីរបៀបគូសសញ្ញាជ្រើសរើសក្នុងប្រអប់ដែលត្រូវនឹងសកម្មភាពសិក្សារបស់សិស្ស ហើយការធ្វើកម្រងសំណួរនេះមានរយៈពេលចន្លោះពី ៣០ ទៅ ៤៥នាទី។

## ៣.៤- ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបរិមាណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទសំណាកនីមួយៗ ( សិស្សតាមបណ្តុំមុខវិជ្ជា និងភេទ)។ ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើកម្មវិធីកុំព្យូទ័រសម្រាប់ការស្រាវជ្រាវ សម្រាប់ការវិភាគទិន្នន័យដោយប្រើស្ថិតិដូចខាងក្រោម៖

១-ស្ថិតិមូលដ្ឋានដែលប្រើរកស្ថានភាពរបស់អ្នកឆ្លើយក្នុងកម្រងសំណួរ វិភាគដោយប្រើ Descriptives ។

២-ស្ថិតិដែលប្រើវិភាគកម្រងសំណួរអំពីទស្សនៈការយល់ឃើញអំពី *យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម* វិភាគដោយប្រើ Mean និង Standard Deviation។ *(មើលឧបសម្ព័នទី ៤)*

៣-ស្ថិតិដែលប្រើវិភាគកម្រងសំណួរអំពីទស្សនៈការយល់ឃើញអំពី *យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម* វិភាគដោយប្រើ Independent Sample-t Test។ *(មើលឧបសម្ព័នទី ៦)*

៤-ស្ថិតិដែលប្រើរកភាពជឿជាក់របស់កម្រងសំណួរ ដោយការរកតម្លៃសហប្រសិទ្ធភាពអ៊ែលហ្វារបស់គ្រន់ប៉ាគ (Cronbach's Alpha Coefficient)

## ៣.៥- ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌មានសារៈសំខាន់ណាស់ សម្រាប់អ្នកសិក្សាស្រាវជ្រាវក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាបង្កើននូវទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ ក៏ដូចជាទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ ការព្រមព្រាងគ្នារវាងអ្នកចូលរួមធ្វើកម្រងសំណួរ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសំងាត់លើកលែងតែឈ្មោះសាលារៀនដែលត្រូវបានបង្ហាញ ក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយៗ អ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលបំពេញកម្រងសំណួរ។ ការចូលរួមសហការរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូក្នុងការផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវចុះធ្វើកម្រងសំណួរតាមថ្នាក់ មានន័យថា អ្នកពាក់ព័ន្ធទាំងនោះយល់នូវគោលបំណង នៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយ ឬព័ត៌មានពិត។ ការធ្វើដូច្នេះ ធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី ៤
# លទ្ធផលការស្រាវជ្រាវ

# ជំពូកទី៤

# លទ្ធផលការស្រាវជ្រាវ

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ ការបកស្រាយ និងការវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និងការធ្វើតេស្ត ដើម្បីឲ្យដឹងថា តើសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម ប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសដូចម្តេច និងដើម្បីឲ្យដឹងថាអ្វីខ្លះជាបញ្ហាប្រឈមក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសនាពេលបច្ចុប្បន្ន។

## ៤.១- លទ្ធផលការស្រាវជ្រាវសំណួរទី១៖ តើយុទ្ធសាស្ត្រសិក្សាវាក្យសព្ទអ្វីដែលសិស្សប្រើ?

នៅក្នុងសំណួរទី១នេះអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតសិក្សារបស់សិស្ស នៅកម្រិតមធ្យមសិក្សាទុតិភូមិក្នុងការប្រើយុទ្ធសាស្ត្រ រៀនវាក្យសព្ទភាសាអង់គ្លសនៅខេត្តកំពង់ចាមចំនួន ៣៥៥ នាក់ ស្រី ១៩២ នាក់ ចំនួន ១០ ថ្នាក់ មកពីវិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម។

ឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានចំនួន ៤០ ចំណុចបែងចែកជា ៤ ផ្នែក៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) ដើម្បីបង្ហាញឲ្យឃើញនូវកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្ស។ យោងតាមការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995) កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺកម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និងកម្រិតទាម (M=2.49 ចុះ)។

**តារាងទី២៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ** ( N= 355 )

| ល.រ | ខ្លឹមសារ | កម្រិតការអនុវត្ត | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដារ | | |
| ១ | ខ្ញុំសរសេរពាក្យម្តងហើយម្តងទៀតដើម្បីចងចាំវា។ | ២.៥៥ | ១.០១ | មធ្យម | ១៩ |
| ២ | ខ្ញុំរំលឹកឡើងវិញនូវពាក្យដែលខ្ញុំបានរៀនម្តងហើយម្តងទៀត។ | ២.៨៦ | ១.១០ | មធ្យម | ១០ |
| ៣ | ខ្ញុំសរសេរពាក្យជាបញ្ជីដើម្បីជួយឲ្យខ្ញុំចងចាំវា។ | ២.៣៦ | ១.២៥ | ទាប | ២៩ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ខ្ញុំសួរខ្លួនឯងនៅលើបញ្ជីពាក្យរហូតដល់ខ្ញុំចងចាំវា។ | ២.៣៧ | ១.២១ | ទាប | ២៨ |
| ៥ | ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា។ | ៣.២៨ | ១.៣០ | មធ្យម | ៣ |
| ៦ | ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ។ | ២.០៥ | ១.១៧ | ទាប | ៣៧ |
| ៧ | ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត។ | ១.៩៧ | ១.១៣ | ទាប | ៣៩ |
| ៨ | ខ្ញុំស្តាប់ការថតពាក្យជាច្រើនដងដើម្បីជួយខ្ញុំឲ្យចាំពីរបៀបដែលវាបញ្ចេញសំឡេង។ | ២.៥០ | ១.២៤ | មធ្យម | ២៣ |
| ៩ | ខ្ញុំបែងចែកជាប្រភេទ (គ្រឿងសង្ហារឹម, ពណ៌ជាដើម) ដើម្បីឲ្យខ្ញុំចងចាំវា។ | ២.០៦ | ១.២៤ | ទាប | ៣៥ |
| ១០ | ខ្ញុំចាំពាក្យដោយភ្ជាប់ជាមួយពេលដែលខ្ញុំបានរៀន។ | ៣.០២ | ១.១២ | មធ្យម | ៧ |
| ១១ | ខ្ញុំប្រើពាក្យគន្លឹះ (ភ្ជាប់ពាក្យមួយទៅពាក្យមួយទៀត) ដើម្បីជួយខ្ញុំរៀន។ | ២.៥០ | ១.២៦ | មធ្យម | ២៤ |
| ១២ | ខ្ញុំចាំពាក្យដោយភ្ជាប់ទំនាក់ទំនងវាជាមួយទីតាំងដែលខ្ញុំបានឃើញ។ | ២.៥៥ | ១.១៩ | មធ្យម | ២០ |
| ១៣ | ខ្ញុំភ្ជាប់ពាក្យដែលទាក់ទងផ្សេងទៀតទៅនឹងអ្វីដែលខ្ញុំកំពុងរៀន។ | ២.៦៨ | ១.១៨ | មធ្យម | ១៦ |
| ១៤ | ខ្ញុំភ្ជាប់រូបភាពទៅនឹងពាក្យដើម្បីជួយខ្ញុំចងចាំវា។ | ២.៥៣ | ១.២៤ | មធ្យម | ២១ |
| ១៥ | ខ្ញុំភ្ជាប់ពាក្យទៅនឹងឃ្លា ប្រយោគ ឬអត្ថបទដែលខ្ញុំឃើញ។ | ២.៤៩ | ១.២៤ | ទាប | ២៥ |
| ១៦ | ខ្ញុំបង្កើតឃ្លាខ្លីៗ (បង្កើតឃ្លាដើម្បីភ្ជាប់អត្ថន័យ) ដើម្បីឲ្យចងចាំពាក្យ។ | ២.៧៧ | ១.៣០ | មធ្យម | ១៤ |
| ១៧ | ខ្ញុំភ្ជាប់ពាក្យទៅនឹងពាក្យដែលមានន័យដូច ឬន័យផ្ទុយរបស់វាដើម្បីជួយខ្ញុំចងចាំវា។ | ២.៣៩ | ១.២២ | ទាប | ២៧ |
| ១៨ | ខ្ញុំប្រើពាក្យស្រដៀងគ្នាដើម្បីឲ្យឆាប់ចាំ។ | ២.៧៣ | ១.២៧ | មធ្យម | ១៥ |
| ១៩ | ខ្ញុំព្យាយាមភ្ជាប់ពាក្យភាសាអង់គ្លេសទៅនឹងភាសារបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យចងចាំ។ | ២.៩៥ | ១.២៥ | មធ្យម | ៩ |
| ២០ | ខ្ញុំចាំពាក្យខ្លះៗតាមវិធីដែលវាផ្លាស់ប្តូរដោយប្រើវេយ្យាករណ៍ជាភាសាអង់គ្លេស។ | ២.៤៤ | ១.១៨ | ទាប | ២៦ |

| | | | | | |
|---|---|---|---|---|---|
| ២១ | ខ្ញុំដាក់ក្រុមពាក្យទៅតាមប្រភេទដើម្បីងាយចាំ (សត្វ ការងារ សម្លៀកបំពាក់...)។ | ២.៥១ | ១.២៦ | មធ្យម | ២២ |
| ២២ | ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ។ | ៣.៤៣ | ១.២៥ | មធ្យម | ២ |
| ២៣ | ខ្ញុំហ្វឹកហាត់ប្រើពាក្យដើម្បីចងចាំវាឲ្យបានប្រសើរជាងមុន។ | ៣.០២ | ១.២៥ | មធ្យម | ៨ |
| ២៤ | ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ។ | ១.៨៤ | ១.០៣ | ទាប | ៤០ |
| ២៥ | ខ្ញុំសិក្សាពាក្យទាំងអស់ជាមួយរូបភាពដែលបង្ហាញពីអត្ថន័យរបស់វា។ | ២.៣៣ | ១.១០ | ទាប | ៣១ |
| ២៦ | ខ្ញុំព្យាយាមកំណត់អត្ថន័យវានៅពេលរៀនដើម្បីឲ្យដឹងថាខ្ញុំចេះវា ឬអត់។ | ២.៨១ | ១.២០ | មធ្យម | ១១ |
| ២៧ | ខ្ញុំបង្កើតពាក្យចួនដើម្បីជួយខ្ញុំឲ្យចងចាំ។ | ២.១៩ | ១.១៩ | ទាប | ៣៤ |
| ២៨ | ខ្ញុំចាំពាក្យដែលមានសំឡេងស្រដៀងគ្នា។ | ២.៧៧ | ១.១៧ | មធ្យម | ១៣ |
| ២៩ | ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)។ | ១.៩៩ | ១.១៤ | ទាប | ៣៨ |
| ៣០ | ខ្ញុំនិយាយ និងសរសេរពាក្យភាសាអង់គ្លេសដែលខ្ញុំកំពង់រៀនតាមតែអាចធ្វើបាន។ | ៣.១៤ | ១.២៤ | មធ្យម | ៦ |
| ៣១ | ខ្ញុំហាត់ប្រើពាក្យថ្មីដោយធ្វើការសន្ទនាជាមួយមិត្តភក្តិ ឬជនបរទេស។ | ២.២៩ | ១.២២ | ទាប | ៣៣ |
| ៣២ | ខ្ញុំហាត់ប្រើពាក្យជាមួយមិត្តរួមថ្នាក់ ឬមិត្តភក្តិដើម្បីជួយឲ្យខ្ញុំចាំពាក្យបានល្អ។ | ២.៦៦ | ១.១៥ | មធ្យម | ១៧ |
| ៣៣ | ខ្ញុំមើលវីដេអូ ស្តាប់បទចម្រៀង ឬស្តាប់វិទ្យុជាភាសាអង់គ្លេសដើម្បីស្គាល់ពាក្យថ្មី និងដឹងពីរបៀបប្រើ។ | ២.៨០ | ១.៣៩ | មធ្យម | ១២ |
| ៣៤ | ខ្ញុំតែងតែកត់ត្រាពាក្យថ្មីនៅពេលដែលខ្ញុំមើលខ្សែរភាពយន្ត ឬកម្មវិធីទូរទស្សន៍។ | ២.៣៦ | ១.២៧ | ទាប | ៣០ |
| ៣៥ | ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យនិងការប្រើប្រាស់របស់វា។ | ៣.២៣ | ១.២៧ | មធ្យម | ៤ |
| ៣៦ | ខ្ញុំសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ។ | ៣.៥២ | ១.១៩ | ខ្ពស់ | ១ |
| ៣៧ | ខ្ញុំកត់ចំណាំនៅពេលខ្ញុំឃើញពាក្យថ្មី។ | ៣.២១ | ១.២៤ | មធ្យម | ៥ |

| | | | | | |
|---|---|---|---|---|---|
| ៣៨ | ខ្ញុំដាក់សៀវភៅកត់ពាក្យនៅជាប់ខ្លួនជានិច្ច។ | ២.៥៧ | ១.៣៦ | មធ្យម | ១៨ |
| ៣៩ | ខ្ញុំលេងល្បែងប្រដេញពាក្យ។ | ២.៣០ | ១.២០ | ទាប | ៣២ |
| ៤០ | ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗជាភាសាអង់គ្លេស។ | ២.០៥ | ១.១៤ | ទាប | ៣៦ |
| **សរុប** | | **២.៦០** | ០.៦៣ | មធ្យម | |

យោងតាមតារាងខាងលើ លទ្ធផលបានបង្ហាញថាសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្រ្តរៀនវាក្យសព្ទភាសាអង់គ្លេស ចាប់កម្រិតខ្ពស់ ពី ៣.៥២ រហូតដល់ កម្រិតទាប ១.៨៤។ នេះមានន័យថា ចំណុច ៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ គឺមានកម្រិត មធ្យមខ្ពស់ ៣.៥២ (M=3.52) បន្ទាប់មកទៀតគឺចំណុច ២២៖ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ដែលមានកម្រិតមធ្យម ៣.៤៣ (M=3.43) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.២៨ (M=3.28)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨៤ (M=1.84) បន្ទាប់មកមានចំណុចទី ៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៩៧ (M=1.97) និងចំណុចចុងក្រោយគឺ ចំណុច ២៩៖ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យម ១.៩៩ (M=1.99)។

ជារួមតាមរាងខាងលើបង្ហាញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សតាមរយៈការសួរមិត្តភក្តិលោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្រ្តរៀនតាមរយៈការបំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុត។

នៅតារាងទី២ខាងក្រោម អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញពីកម្រិតនៃការប្រើយុទ្ធសាស្រ្តរៀនរបស់សិស្សជាផ្នែក ដើម្បីឲ្យដឹងពីកម្រិតខ្ពស់ ឬទាបតាមផ្នែកនីមួយៗ។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្រ្តរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិ ចំនួន ៣៥៥ នាក់ ស្រី ១៩២ នាក់ ចំនួន ១០ ថ្នាក់ មកពីវិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ទៅតាមផ្នែកនីមួយៗនៃកម្រងសំណួរជ្រើសរើសផងដែរ។

ឧបករណ៍ស្រាវជ្រាវ ផ្នែកទាំងបួននៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦)ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

**តារាងទី៣៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់** (N=៣៥៥)

| ល.រ | ខ្លឹមសារ | កម្រិតការអនុវត្ត | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដារ | | |
| **ផ្នែកទី១៖ ការបង្កើតពាក្យ** | | | | | |
| ១ | ខ្ញុំសរសេរពាក្យម្តងហើយម្តងទៀតដើម្បីចងចាំវា។ | ២.៥៥ | ១.០១ | មធ្យម | ១៩ |
| ២ | ខ្ញុំរំលឹកឡើងវិញនូវពាក្យដែលខ្ញុំបានរៀនម្តងហើយម្តងទៀត។ | ២.៨៦ | ១.១០ | មធ្យម | ១០ |
| ៣ | ខ្ញុំសរសេរពាក្យជាបញ្ជីដើម្បីជួយឲ្យខ្ញុំចងចាំវា។ | ២.៣៦ | ១.២៥ | ទាប | ២៩ |
| ៤ | ខ្ញុំសួរខ្លួនឯងនៅលើបញ្ជីពាក្យរហូតដល់ខ្ញុំចងចាំវា។ | ២.៣៧ | ១.២១ | ទាប | ២៨ |
| ៥ | ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា។ | ៣.២៨ | ១.៣០ | មធ្យម | ៣ |
| ៦ | ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ។ | ២.០៥ | ១.១៧ | ទាប | ៣៧ |
| **សរុប** | | **២.៥៨** | **០.៧៣៧** | | |
| **ផ្នែកទី២៖ ការតាមដានការប្រើពាក្យ** | | | | | |
| ៧ | ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត។ | ១.៩៧ | ១.១៣ | ទាប | ៣៩ |
| ៨ | ខ្ញុំស្តាប់ការថតពាក្យជាច្រើនដងដើម្បីជួយខ្ញុំឲ្យចាំពីរបៀបដែលវាបញ្ចេញសំឡេង។ | ២.៥០ | ១.២៤ | មធ្យម | ២៣ |
| ៩ | ខ្ញុំបែងចែកជាប្រភេទ (គ្រឿងសង្ហារឹម, ពណ៌ជាដើម) ដើម្បីឲ្យខ្ញុំចងចាំវា។ | ២.០៦ | ១.២៤ | ទាប | ៣៥ |
| ១០ | ខ្ញុំចាំពាក្យដោយភ្ជាប់ជាមួយពេលដែលខ្ញុំបានរៀន។ | ៣.០២ | ១.១២ | មធ្យម | ៧ |
| ១១ | ខ្ញុំប្រើពាក្យគន្លឹះ (ភ្ជាប់ពាក្យមួយទៅពាក្យមួយទៀត) ដើម្បីជួយខ្ញុំរៀន។ | ២.៥០ | ១.២៦ | មធ្យម | ២៤ |
| ១២ | ខ្ញុំចាំពាក្យដោយភ្ជាប់ទំនាក់ទំនងវាជាមួយទីតាំងដែលខ្ញុំបានឃើញ។ | ២.៥៥ | ១.១៩ | មធ្យម | ២០ |
| ១៣ | ខ្ញុំភ្ជាប់ពាក្យដែលទាក់ទងផ្សេងទៀតទៅនឹងអ្វីដែលខ្ញុំកំពុងរៀន។ | ២.៦៨ | ១.១៨ | មធ្យម | ១៦ |

| | | | | | |
|---|---|---|---|---|---|
| ១៤ | ខ្ញុំភ្ជាប់រូបភាពទៅនឹងពាក្យដើម្បីជួយខ្ញុំចងចាំវា។ | ២.៥៣ | ១.២៤ | មធ្យម | ២១ |
| ១៥ | ខ្ញុំភ្ជាប់ពាក្យទៅនឹងឃ្លា ប្រយោគ ឬអត្ថបទដែលខ្ញុំឃើញ។ | ២.៤៩ | ១.២៤ | ទាប | ២៥ |
| ១៦ | ខ្ញុំបង្កើតឃ្លាខ្លីៗ (បង្កើតឃ្លាដើម្បីភ្ជាប់អត្ថន័យ) ដើម្បីឲ្យចងចាំពាក្យ។ | ២.៧៧ | ១.៣០ | មធ្យម | ១៤ |
| ១៧ | ខ្ញុំភ្ជាប់ពាក្យទៅនឹងពាក្យដែលមានន័យដូច ឬន័យផ្ទុយរបស់វាដើម្បីជួយខ្ញុំចងចាំវា។ | ២.៣៩ | ១.២២ | ទាប | ២៧ |
| **សរុប** | | **២.៥០** | **០.៧០៨** | | |
| **ផ្នែកទី៣៖ ទំនាក់ទំនងនៃការប្រើពាក្យ** | | | | | |
| ១៨ | ខ្ញុំប្រើពាក្យស្រដៀងគ្នាដើម្បីឲ្យឆាប់ចាំ។ | ២.៧៣ | ១.២៧ | មធ្យម | ១៥ |
| ១៩ | ខ្ញុំព្យាយាមភ្ជាប់ពាក្យភាសាអង់គ្លេសទៅនឹងភាសារបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យចងចាំ។ | ២.៩៥ | ១.២៥ | មធ្យម | ៩ |
| ២០ | ខ្ញុំចាំពាក្យខ្លះៗតាមវិធីដែលវាផ្លាស់ប្ដូរដោយប្រើវេយ្យាករណ៍ជាភាសាអង់គ្លេស។ | ២.៤៤ | ១.១៨ | ទាប | ២៦ |
| ២១ | ខ្ញុំដាក់ក្រុមពាក្យទៅតាមប្រភេទដើម្បីងាយចាំ (សត្វ ការងារ សម្លៀកបំពាក់...)។ | ២.៥១ | ១.២៦ | មធ្យម | ២២ |
| ២២ | ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ។ | ៣.៤៣ | ១.២៥ | មធ្យម | ២ |
| ២៣ | ខ្ញុំហ្វឹកហាត់ប្រើពាក្យដើម្បីចងចាំវាឲ្យបានប្រសើរជាងមុន។ | ៣.០២ | ១.២៥ | មធ្យម | ៨ |
| ២៤ | ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ។ | ១.៨៤ | ១.០៣ | ទាប | ៤០ |
| ២៥ | ខ្ញុំសិក្សាពាក្យទាំងអស់ជាមួយរូបភាពដែលបង្ហាញពីអត្ថន័យរបស់វា។ | ២.៣៣ | ១.១០ | ទាប | ៣១ |
| ២៦ | ខ្ញុំព្យាយាមកំណត់អត្ថន័យវានៅពេលរៀនដើម្បីឲ្យដឹងថាខ្ញុំចេះវា ឬអត់។ | ២.៨១ | ១.២០ | មធ្យម | ១១ |
| ២៧ | ខ្ញុំបង្កើតពាក្យចួនដើម្បីជួយខ្ញុំឲ្យចងចាំ។ | ២.១៩ | ១.១៩ | ទាប | ៣៤ |
| ២៨ | ខ្ញុំចាំពាក្យដែលមានសំឡេងស្រដៀងគ្នា។ | ២.៧៧ | ១.១៧ | មធ្យម | ១៣ |
| ២៩ | ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)។ | ១.៩៩ | ១.១៤ | ទាប | ៣៨ |

| | | | | | |
|---|---|---|---|---|---|
| ៣០ | ខ្ញុំនិយាយ និងសរសេរពាក្យភាសាអង់គ្លេស ដែលខ្ញុំកំពង់រៀនតាមតែអាចធ្វើបាន។ | ៣.១៤ | ១.២៤ | មធ្យម | ៦ |
| **សរុប** | | **២.៦២** | **០.៦៧៣** | មធ្យម | |
| **ផ្នែកទី៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ** | | | | | |
| ៣១ | ខ្ញុំហាត់ប្រើពាក្យថ្មីដោយធ្វើការសន្ទនា ជាមួយមិត្តភក្តិ ឬជនបរទេស។ | ២.២៩ | ១.២២ | ទាប | ៣៣ |
| ៣២ | ខ្ញុំហាត់ប្រើពាក្យជាមួយមិត្តរួមថ្នាក់ ឬមិត្តភក្តិ ដើម្បីជួយឲ្យខ្ញុំចាំពាក្យបានល្អ។ | ២.៦៦ | ១.១៥ | មធ្យម | ១៧ |
| ៣៣ | ខ្ញុំមើលវីដេអូ ស្តាប់បទចម្រៀង ឬស្តាប់វិទ្យុជាភាសាអង់គ្លេសដើម្បីស្គាល់ពាក្យថ្មី និងដឹងពីរបៀបប្រើ។ | ២.៨០ | ១.៣៩ | មធ្យម | ១២ |
| ៣៤ | ខ្ញុំតែងតែកត់ត្រាពាក្យថ្មីនៅពេលដែលខ្ញុំមើល ខ្សែរភាពយន្ត ឬកម្មវិធីទូរទស្សន៍។ | ២.៣៦ | ១.២៧ | ទាប | ៣០ |
| ៣៥ | ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យ និងការប្រើប្រាស់របស់វា។ | ៣.២៣ | ១.២៧ | មធ្យម | ៤ |
| ៣៦ | ខ្ញុំសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវ ពាក្យដែលខ្ញុំមិនចេះ។ | ៣.៥២ | ១.១៩ | ខ្ពស់ | ១ |
| ៣៧ | ខ្ញុំកត់ចំណាំនៅពេលខ្ញុំឃើញ ពាក្យថ្មី។ | ៣.២១ | ១.២៤ | មធ្យម | ៥ |
| ៣៨ | ខ្ញុំដាក់សៀវភៅកត់ពាក្យនៅជាប់ ខ្លួនជានិច្ច។ | ២.៥៧ | ១.៣៦ | មធ្យម | ១៨ |
| ៣៩ | ខ្ញុំលេងល្បែង ប្រដេញពាក្យ។ | ២.៣០ | ១.២០ | ទាប | ៣២ |
| ៤០ | ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗ ជាភាសាអង់គ្លេស។ | ២.០៥ | ១.១៤ | ទាប | ៣៦ |
| **សរុប** | | **២.៧០** | **០.៧០** | | |
| **សរុបរួម** | | **២.៦០** | **០.៦៣** | មធ្យម | |

តាមតារាងនៃការបែងចែកជាផ្នែកខាងលើបានបង្ហាញលទ្ធផលថា សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសតាមផ្នែក មានកម្រិតមធ្យម ខ្ពស់ចាប់ពី ២.៧០ រហូតដល់ កម្រិតទាប ២.៥០ និងមានកម្រិតមធ្យម ២.៦០ (M=2.60)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យមខ្ពស់ជាងគេ ២.៧០ (M=2.70) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦២ (M=2.62) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៨ (M=2.58) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៥០ (M=2.៥0)។

នេះក៏សបញ្ជាក់ឲ្យឃើញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែលគ្នាដែលផ្នែកទី ៤ មានកកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៧0 (M=2.70) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៥0 (M=2.50)។

ចំណែកឯតារាងបន្ទាប់អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សតាមភេទវិញម្តង។ ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិទៅតាមភេទផ្សេងគ្នា (ប្រុស និងស្រី) ដើម្បីឲ្យដឹងពីរបៀប និងយុទ្ធសាស្ត្រក្នុងការរៀនភាសារបស់ពួកគេ។

ឧបករណ៍ស្រាវជ្រាវ ផ្នែកទាំងបួននៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦)ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣0) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១0 ចំណុច ចាប់ពី ៣១ ដល់ ៤0)។

**តារាងទី៤៖ មធ្យម គម្លាតស្តង់ដារនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិតាមភេទ** (N=**៣៥៥**)

| ល.រ | ខ្លឹមសារ | ប្រុស | | ស្រី | |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដារ | មធ្យម | គម្លាតស្តង់ដារ |
| ១ | ខ្ញុំសរសេរពាក្យម្តងហើយម្តងទៀតដើម្បីចងចាំវា។ | ២.៥៥ | ១.0៨ | ២.៥៥ | 0.៩៤ |
| ២ | ខ្ញុំរំលឹកឡើងវិញនូវពាក្យដែលខ្ញុំបានរៀនម្តងហើយម្តងទៀត។ | ២.៨៨ | ១.១៧ | ២.៨៥ | ១.0៤ |
| ៣ | ខ្ញុំសរសេរពាក្យជាបញ្ជីដើម្បីជួយឲ្យខ្ញុំចងចាំវា។ | ២.៤0 | ១.៣0 | ២.៣២ | ១.២១ |
| ៤ | ខ្ញុំសួរខ្លួនឯងនៅលើបញ្ជីពាក្យរហូតដល់ខ្ញុំចងចាំវា។ | ២.៣៤ | ១.១៨ | ២.៤0 | ១.២៣ |
| ៥ | ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា។ | ៣.១៧ | ១.៣១ | ៣.៣៨ | ១.២៨ |
| ៦ | ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ។ | ២.១២ | ១.២៥ | ១.៩៩ | ១.0៩ |
| ៧ | ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត។ | ២.0៦ | ១.១៤ | ១.៩0 | ១.១២ |
| ៨ | ខ្ញុំស្តាប់ការថតពាក្យជាច្រើនដងដើម្បីជួយខ្ញុំឲ្យចាំពីរបៀបដែលវាបញ្ចេញសំឡេង។ | ២.៥២ | ១.២២ | ២.៤៩ | ១.២៧ |

| | | | | | |
|---|---|---|---|---|---|
| ៩ | ខ្ញុំបែងចែកជាប្រភេទ (គ្រឿងសង្ហារឹម, ពណ៌ ជាដើម) ដើម្បីឲ្យខ្ញុំចងចាំវា។ | ២.០៨ | ១.២៧ | ២.០៥ | ១.២២ |
| ១០ | ខ្ញុំចាំពាក្យដោយភ្ជាប់ជាមួយពេលដែល ខ្ញុំបានរៀន។ | ២.៩៩ | ១.១១ | ៣.០៤ | ១.១៤ |
| ១១ | ខ្ញុំប្រើពាក្យគន្លឹះ (ភ្ជាប់ពាក្យមួយទៅពាក្យ មួយទៀត) ដើម្បីជួយខ្ញុំរៀន។ | ២.៤២ | ១.២៦ | ២.៥៨ | ១.២៦ |
| ១២ | ខ្ញុំចាំពាក្យដោយភ្ជាប់ទំនាក់ទំនងវាជាមួយ ទីតាំងដែលខ្ញុំបានឃើញ។ | ២.៥៩ | ១.២១ | ២.៥៣ | ១.១៨ |
| ១៣ | ខ្ញុំភ្ជាប់ពាក្យដែលទាក់ទងផ្សេងទៀតទៅនឹង អ្វីដែលខ្ញុំកំពុងរៀន។ | ២.៥៨ | ១.១៣ | ២.៧៦ | ១.២១ |
| ១៤ | ខ្ញុំភ្ជាប់រូបភាពទៅនឹងពាក្យដើម្បីជួយ ខ្ញុំចងចាំវា។ | ២.៦១ | ១.២៩ | ២.៤៧ | ១.២០ |
| ១៥ | ខ្ញុំភ្ជាប់ពាក្យទៅនឹងឃ្លា ប្រយោគ ឬអត្ថបទ ដែលខ្ញុំឃើញ។ | ២.២៨ | ១.១៧ | ២.៦៧ | ១.២៦ |
| ១៦ | ខ្ញុំបង្កើតឃ្លាខ្លីៗ (បង្កើតឃ្លាដើម្បីភ្ជាប់អត្ថន័យ) ដើម្បីឲ្យចងចាំពាក្យ។ | ២.៦៧ | ១.២៩ | ២.៨៦ | ១.៣១ |
| ១៧ | ខ្ញុំភ្ជាប់ពាក្យទៅនឹងពាក្យដែលមានន័យដូច ឬ ន័យផ្ទុយរបស់វាដើម្បីជួយខ្ញុំចងចាំវា។ | ២.៣០ | ១.២៤ | ២.៤៦ | ១.២១ |
| ១៨ | ខ្ញុំប្រើពាក្យស្រដៀងគ្នាដើម្បីឲ្យ ឆាប់ចាំ។ | ២.៧៧ | ១.២៦ | ២.៧០ | ១.២៨ |
| ១៩ | ខ្ញុំព្យាយាមភ្ជាប់ពាក្យភាសាអង់គ្លេសទៅនឹង ភាសារបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យចងចាំ។ | ២.៨៣ | ១.៣១ | ៣.០៥ | ១.១៩ |
| ២០ | ខ្ញុំចាំពាក្យខ្លះៗតាមវិធីដែលវាផ្លាស់ប្តូរដោយ ប្រើវេយ្យាករណ៍ជាភាសាអង់គ្លេស។ | ២.៣៧ | ១.១២ | ២.៤៩ | ១.២៣ |
| ២១ | ខ្ញុំដាក់ក្រុមពាក្យទៅតាមប្រភេទដើម្បីងាយចាំ (សត្វ ការងារ សម្លៀកបំពាក់...)។ | ២.៥២ | ១.២៩ | ២.៥០ | ១.២៣ |
| ២២ | ខ្ញុំព្យាយាមចងចាំពាក្យដោយ ការប្រកប ។ | ៣.៤០ | ១.៣១ | ៣.៤៤ | ១.១៩ |
| ២៣ | ខ្ញុំហ្វឹកហាត់ប្រើពាក្យដើម្បីចងចាំវា ឲ្យបានប្រសើរជាងមុន។ | ២.៩៤ | ១.២៣ | ៣.០៨ | ១.២៧ |
| ២៤ | ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយ ខ្ញុំរៀនវាឲ្យឆាប់ចាំ។ | ១.៨៨ | ១.០៥ | ១.៨០ | ១.០១ |
| ២៥ | ខ្ញុំសិក្សាពាក្យទាំងអស់ជាមួយរូបភាពដែល បង្ហាញពីអត្ថន័យរបស់វា។ | ២.២៥ | ១.១៣ | ២.៣៩ | ១.០៨ |

| | | | | | |
|---|---|---|---|---|---|
| ២៦ | ខ្ញុំព្យាយាមកំណត់អត្ថន័យវានៅពេលរៀន ដើម្បីឲ្យដឹងថាខ្ញុំចេះវា ឬអត់។ | ២.៨៤ | ១.២០ | ២.៧៨ | ១.២១ |
| ២៧ | ខ្ញុំបង្កើតពាក្យចួនដើម្បីជួយ ខ្ញុំឲ្យចងចាំ។ | ២.២០ | ១.២២ | ២.១៨ | ១.១៧ |
| ២៨ | ខ្ញុំចាំពាក្យដែលមានសំឡេង ស្រដៀងគ្នា។ | ២.៦៥ | ១.១៨ | ២.៨៦ | ១.១៥ |
| ២៩ | ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)។ | ១.៨៧ | ១.០៣ | ២.០៨ | ១.២១ |
| ៣០ | ខ្ញុំនិយាយ និងសរសេរពាក្យភាសាអង់គ្លេស ដែលខ្ញុំកំពង់រៀនតាមតែអាចធ្វើបាន។ | ៣.០០ | ១.៣២ | ៣.២៦ | ១.១៦ |
| ៣១ | ខ្ញុំហាត់ប្រើពាក្យថ្មីដោយធ្វើការសន្ទនា ជាមួយមិត្តភក្តិ ឬជនបរទេស។ | ២.១៩ | ១.២១ | ២.៣៧ | ១.២២ |
| ៣២ | ខ្ញុំហាត់ប្រើពាក្យជាមួយមិត្តរួមថ្នាក់ ឬមិត្តភក្តិ ដើម្បីជួយឲ្យខ្ញុំចាំពាក្យបានល្អ។ | ២.៦១ | ១.២០ | ២.៦៩ | ១.១១ |
| ៣៣ | ខ្ញុំមើលវីដេអូ ស្តាប់បទចម្រៀង ឬស្តាប់វិទ្យុជាភាសាអង់គ្លេសដើម្បីស្គាល់ពាក្យថ្មី និងដឹងពីរបៀបប្រើ។ | ២.៨១ | ១.៤៤ | ២.៨០ | ១.៣៦ |
| ៣៤ | ខ្ញុំតែងតែកត់ត្រាពាក្យថ្មីនៅពេលដែលខ្ញុំមើល ខ្សែរភាពយន្ត ឬកម្មវិធីទូរទស្សន៍។ | ២.៣៦ | ១.២៥ | ២.៣៥ | ១.២៩ |
| ៣៥ | ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យ និងការប្រើប្រាស់របស់វា។ | ៣.១១ | ១.២៨ | ៣.៣៣ | ១.២៧ |
| ៣៦ | ខ្ញុំសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវ ពាក្យដែលខ្ញុំមិនចេះ។ | ៣.៥០ | ១.២៣ | ៣.៥៣ | ១.១៦ |
| ៣៧ | ខ្ញុំកត់ចំណាំនៅពេលខ្ញុំឃើញ ពាក្យថ្មី។ | ៣.១៤ | ១.៣១ | ៣.២៧ | ១.១៨ |
| ៣៨ | ខ្ញុំដាក់សៀវភៅកត់ពាក្យនៅជាប់ ខ្លួនជានិច្ច។ | ២.៤៨ | ១.៣៤ | ២.៦៤ | ១.៣៨ |
| ៣៩ | ខ្ញុំលេងល្បែង ប្រដេញពាក្យ។ | ២.១៣ | ១.២១ | ២.៤៤ | ១.១៧ |
| ៤០ | ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗ ជាភាសាអង់គ្លេស។ | ១.៩៤ | ១.០៧ | ២.១៤ | ១.១៩ |
| **សរុប** | | ២.៥៦ | ០.៦៣ | ២.៦៣ | ០.៦២ |

យោងតាមតារាងខាងលើបង្ហាញថា ការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម របស់សិស្សប្រុស មានកម្រិតខ្ពស់ចាប់ពី ៣.៥០ រហូតដល់

កម្រិតទាបបំផុត ១.៨៧ និងមានកម្រិតមធ្យម ២.៥៦។ នេះមានន័យថា ចំណុច៣៦៖ សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ ដែលមានកម្រិតខ្ពស់ ៣.៥០ (M=3.50) បន្ទាប់មកទៀតគឺចំណុច ២២៖ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប គឺមានកម្រិត មធ្យម ៣.៤០ (M=3.40) និងកម្រិតមធ្យមចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.១៧ (M=3.17)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៩៖ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យមទាបបំផុត ១.៨៧ (M=1.87) បន្ទាប់មកមានចំណុចទី ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យមទាបបំផុត ១.៨៨ (M=1.88) និងចំណុចចុងក្រោយគឺ ចំណុច ៤០៖ ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗជាភាសាអង់គ្លេស មានកម្រិតមធ្យមទាប ១.៩៤ (M=1.94) ។

ជារួមតាមរាងខាងលើបង្ហាញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សប្រុស តាមរយៈសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលមិនចេះ មានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្រ្តរៀនតាមរយៈ ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)មានកម្រិតទាបបំផុត។

ចំណែកឯ ការប្រើប្រាស់យុទ្ធសាស្រ្តរៀនវាក្យសព្ទភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម របស់សិស្សស្រី មានកម្រិតខ្ពស់ចាប់ពី ៣.៥៣ រហូតដល់ កម្រិតទាបបំផុត ១.៨០ និងមានកម្រិតមធ្យម ២.៦៣។ មានន័យថា ចំណុច៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ ដែលមានកម្រិតមធ្យម ៣.៥៣ (M=3.53) បន្ទាប់មកទៀតគឺចំណុច ២២៖ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប គឺមានកម្រិត មធ្យម ៣.៤៤ (M=3.44) និងកម្រិតមធ្យមចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.៣៨ (M=3.38)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យមទាបបំផុត ១.៨០ (M=1.80) បន្ទាប់មកមានចំណុចទី ៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតទាប ១.៩០ (M=1.90) និងចំណុចចុងក្រោយគឺ ចំណុច ៦៖ ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ មានកម្រិតមធ្យមទាប ១.៩៩ (M=1.99) ។

នេះបង្ហាញឲ្យឃើញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សស្រី តាមរយៈសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែល មិនចេះ មានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្រ្តរៀនតាមរយៈ ការបំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុត។

សរុបមកការសិក្សាខាងលើបង្ហាញថា ការប្រើយុទ្ធសាស្រ្តរៀនវាក្យសព្ទរបស់សិស្សតាមភេទមានភាពដូចៗ ការសិក្សារបស់ Wafa (2003) ក៏បានបង្ហាញថាមិនមានភាពខុសគ្នារវាងការប្រើយុទ្ធ សាស្រ្តរៀនរបស់សិស្សប្រុស និងសិស្សស្រី។ ដូចនេះការរៀនរបស់សិស្សដែលមានភេទខុសគ្នាមានលក្ខណៈមិនខុសគ្នានោះទេ។

**តារាងទី៥៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់ (N=៣៥៥) តាមភេទ**

ការសិក្សានេះអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិ ដែលមានភេទខុសគ្នាទៅតាមផ្នែក។ ឧបករណ៍ស្រាវជ្រាវ ផ្នែកទាំងបួននៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) ទៅតាមផ្នែកនីមួយៗ ។

| ខ្លឹមសារ | ប្រុស | | | | ស្រី | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដារ | អត្ថន័យ | លំដាប់ | មធ្យម | គម្លាតស្តង់ដារ | អត្ថន័យ | លំដាប់ |
| ១- ការបង្កើតពាក្យ | ២.៥៧ | ០.៧៩ | មធ្យម | ៣ | ២.៥៨ | ០.៦៩ | មធ្យម | ៣ |
| ២- ការតាមដានការប្រើពាក្យ | ២.៤៦ | ០.៧២ | ទាប | ៤ | ២.៥៣ | ០.៧០ | មធ្យម | ៤ |
| ៣- ទំនាក់ទំនងនៃការប្រើពាក្យ | ២.៥៨ | ០.៦៤ | មធ្យម | ២ | ២.៦៦ | ០.៧០ | មធ្យម | ២ |
| ៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ | ២.៦៣ | ០.៧៩ | មធ្យម | ១ | ២.៧៦ | ០.៨០ | មធ្យម | ១ |
| **សរុបរួម** | **២.៥៦** | **០.៦៣** | មធ្យម | | **២.៦៣** | **០.៦២** | មធ្យម | |

តាមតារាងជាផ្នែកខាងលើបានបង្ហាញថា លទ្ធផលថាសិស្សប្រុសនៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសតាមផ្នែក មានកម្រិតខ្ពស់ជាមធ្យមចាប់ពី ២.៦៣ រហូតដល់ កម្រិតទាប ២.៤៦ និងមានកម្រិតមធ្យម ២.៥៦ (M=2.56)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៦៣ (M=2.63) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៥៨ (M=2.58) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៧ (M=2.57) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៤៦ (M=2.46)។

នេះសបញ្ជាក់ឲ្យឃើញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សប្រុសតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែលគ្នាដែលផ្នែកទី ៤ មានកកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតមធ្យមត្រឹម ២.៦៣ (M=2.63) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតទាប ២.៤៦ (M=2.46)។

តារាងដដែលនេះក៏បង្ហាញពីលទ្ធផលរបស់សិស្សស្រី នៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសតាមផ្នែក មានកម្រិតខ្ពស់ចាប់ពី ២.៧៦ រហូតដល់ កម្រិតទាប ២.៥៣ និងមានកម្រិតមធ្យម ២.៦៣ (M=2.63)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៧៦ (M=2.76) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦៦ (M=2.66) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៨ (M=2.58) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៥៣ (M=2.53)។

នេះក៏បានបង្ហាញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សស្រីតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែល គ្នាដែលផ្នែកទី ៤ មានកកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៧៦ (M=2.76) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៥៣ (M=2.53)។

ជារួមការសិក្សាខាងលើបង្ហាញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមភេទមានភាពដូច ឬខុសគ្នាតិចតួចតែប៉ុណ្ណោះ។ ការសិក្សារបស់ Wafa (2003) ក៏បានបង្ហាញថាមិនមានភាពខុសគ្នារវាងការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សប្រុស និងសិស្សស្រី។ ដូចនេះការរៀនរបស់សិស្សដែលមានភេទខុសគ្នាមានលក្ខណៈមិនខុសគ្នានោះទេ។

ចំណែកឯតារាងបន្ទាប់ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សតាមភេទវិញម្តង។

**តារាងទី៦៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់** (N=៣៥៥) **តាមបណ្តុំមុខវិជ្ជា**

ការសិក្សាពីសិស្សតាមបណ្តុំមុខវិជ្ជាដោយសារអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិ ដែលរៀននៅថ្នាក់ផ្សេងគ្នា (ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គម) ។

ការសិក្សានេះអ្នកស្រាវជ្រាវប្រើឧបករណ៍ស្រាវជ្រាវ ផ្នែកទាំងបួននៃកម្រងសំណួរនោះមាន ៖ ផ្នែកទី ១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) ទៅតាមផ្នែកនីមួយៗ ។

| ល.រ | ខ្លឹមសារ | វិទ្យាសាស្ត្រ | | សង្គម | |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដារ | មធ្យម | គម្លាតស្តង់ដារ |

| | | | | | |
|---|---|---|---|---|---|
| ១ | ខ្ញុំសរសេរពាក្យម្តងហើយម្តងទៀតដើម្បីចងចាំវា។ | ២.៦៦ | ០.៩១ | ២.៤៦ | ១.០៧ |
| ២ | ខ្ញុំរំលឹកឡើងវិញនូវពាក្យដែលខ្ញុំបានរៀនម្តងហើយម្តងទៀត។ | ២.៩០ | ១.០៨ | ២.៨៣ | ១.១១ |
| ៣ | ខ្ញុំសរសេរពាក្យជាបញ្ជីដើម្បីជួយឲ្យខ្ញុំចងចាំវា។ | ២.៥៣ | ១.២៤ | ២.២៣ | ១.២៥ |
| ៤ | ខ្ញុំសួរខ្លួនឯងនៅលើបញ្ជីពាក្យរហូតដល់ខ្ញុំចងចាំវា។ | ២.២៤ | ១.១៤ | ២.៤៧ | ១.២៥ |
| ៥ | ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា។ | ៣.៣៥ | ១.២៣ | ៣.២៣ | ១.៣៥ |
| ៦ | ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ។ | ២.១២ | ១.១៩ | ១.៩៩ | ១.១៥ |
| ៧ | ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត។ | ១.៩៤ | ១.១២ | ២.០១ | ១.១៤ |
| ៨ | ខ្ញុំស្តាប់ការថតពាក្យជាច្រើនដងដើម្បីជួយខ្ញុំឲ្យចាំពីរបៀបដែលវាបញ្ចេញសំឡេង។ | ២.៤៤ | ១.១៩ | ២.៥៦ | ១.២៨ |
| ៩ | ខ្ញុំបែងចែកជាប្រភេទ (គ្រឿងសង្ហារឹម, ពណ៌ជាដើម) ដើម្បីឲ្យខ្ញុំចងចាំវា។ | ២.០៣ | ១.២៦ | ២.០៩ | ១.២៣ |
| ១០ | ខ្ញុំចាំពាក្យដោយភ្ជាប់ជាមួយពេលដែលខ្ញុំបានរៀន។ | ៣.១០ | ១.០៣ | ២.៩៥ | ១.១៩ |
| ១១ | ខ្ញុំប្រើពាក្យគន្លឹះ (ភ្ជាប់ពាក្យមួយទៅពាក្យមួយទៀត) ដើម្បីជួយខ្ញុំរៀន។ | ២.៤៤ | ១.២២ | ២.៥៦ | ១.៣០ |
| ១២ | ខ្ញុំចាំពាក្យដោយភ្ជាប់ទំនាក់ទំនងវាជាមួយទីតាំងដែលខ្ញុំបានឃើញ។ | ២.៦៣ | ១.១៥ | ២.៥០ | ១.២២ |
| ១៣ | ខ្ញុំភ្ជាប់ពាក្យដែលទាក់ទងផ្សេងទៀតទៅនឹងអ្វីដែលខ្ញុំកំពុងរៀន។ | ២.៦៩ | ១.០៦ | ២.៦៧ | ១.២៦ |
| ១៤ | ខ្ញុំភ្ជាប់រូបភាពទៅនឹងពាក្យដើម្បីជួយខ្ញុំចងចាំវា។ | ២.៥៨ | ១.២៥ | ២.៥០ | ១.២៣ |
| ១៥ | ខ្ញុំភ្ជាប់ពាក្យទៅនឹងឃ្លា ប្រយោគ ឬអត្ថបទដែលខ្ញុំឃើញ។ | ២.៥១ | ១.២០ | ២.៤៧ | ១.២៧ |
| ១៦ | ខ្ញុំបង្កើតឃ្លាខ្លីៗ (បង្កើតឃ្លាដើម្បីភ្ជាប់អត្ថន័យ) ដើម្បីឲ្យចងចាំពាក្យ។ | ២.៨២ | ១.២៧ | ២.៧៤ | ១.៣៣ |
| ១៧ | ខ្ញុំភ្ជាប់ពាក្យទៅនឹងពាក្យដែលមានន័យដូច ឬន័យផ្ទុយរបស់វាដើម្បីជួយខ្ញុំចងចាំវា។ | ២.៤៣ | ១.២០ | ២.៣៥ | ១.២៥ |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ខ្ញុំប្រើពាក្យស្រដៀងគ្នាដើម្បីឲ្យ<br>ឆាប់ចាំ។ | ២.៧៦ | ១.២០ | ២.៧១ | ១.៣៣ |
| ១៩ | ខ្ញុំព្យាយាមភ្ជាប់ពាក្យភាសាអង់គ្លេសទៅនឹង<br>ភាសារបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យចងចាំ។ | ៣.០១ | ១.១៤ | ២.៩០ | ១.៣២ |
| ២០ | ខ្ញុំចាំពាក្យខ្លះៗតាមវិធីដែលវាផ្លាស់ប្តូរដោយ<br>ប្រើវេយ្យាករណ៍ជាភាសាអង់គ្លេស។ | ២.៥០ | ១.០៩ | ២.៣៩ | ១.២៥ |
| ២១ | ខ្ញុំដាក់ក្រុមពាក្យទៅតាមប្រភេទដើម្បីងាយចាំ<br>(សត្វ ការងារ សម្លៀកបំពាក់...)។ | ២.៥២ | ១.២៤ | ២.៥០ | ១.២៧ |
| ២២ | ខ្ញុំព្យាយាមចងចាំពាក្យដោយ<br>ការប្រកប ។ | ៣.៣២ | ១.២២ | ៣.៥១ | ១.២៦ |
| ២៣ | ខ្ញុំហ្វឹកហាត់ប្រើពាក្យដើម្បីចងចាំវា<br>ឲ្យបានប្រសើរជាងមុន។ | ៣.០២ | ១.១៧ | ៣.០២ | ១.៣១ |
| ២៤ | ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយ<br>ខ្ញុំរៀនវាឲ្យឆាប់ចាំ។ | ១.៨៦ | ១.០០ | ១.៨២ | ១.០៥ |
| ២៥ | ខ្ញុំសិក្សាពាក្យទាំងអស់ជាមួយរូបភាពដែល<br>បង្ហាញពីអត្ថន័យរបស់វា។ | ២.៣០ | ១.០៩ | ២.៣៥ | ១.១២ |
| ២៦ | ខ្ញុំព្យាយាមកំណត់អត្ថន័យវានៅពេលរៀន<br>ដើម្បីឲ្យដឹងថាខ្ញុំចេះវា ឬអត់។ | ២.៩៧ | ១.១៦ | ២.៦៨ | ១.២២ |
| ២៧ | ខ្ញុំបង្កើតពាក្យចួនដើម្បីជួយ<br>ខ្ញុំឲ្យចងចាំ។ | ២.១៨ | ១.១៦ | ២.២០ | ១.២២ |
| ២៨ | ខ្ញុំចាំពាក្យដែលមានសំឡេង<br>ស្រដៀងគ្នា។ | ២.៨២ | ១.១០ | ២.៧២ | ១.២២ |
| ២៩ | ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ<br>(ឧ. នាម, កិ, គុណ,.........)។ | ១.៩៣ | ១.០៥ | ២.០៣ | ១.២០ |
| ៣០ | ខ្ញុំនិយាយ និងសរសេរពាក្យភាសាអង់គ្លេស<br>ដែលខ្ញុំកំពង់រៀនតាមតែអាចធ្វើបាន។ | ៣.២២ | ១.១៦ | ៣.០៨ | ១.៣០ |
| ៣១ | ខ្ញុំហាត់ប្រើពាក្យថ្មីដោយធ្វើការសន្ទនា<br>ជាមួយមិត្តភក្តិ ឬជនបរទេស។ | ២.២២ | ១.១៥ | ២.៣៤ | ១.២៦ |
| ៣២ | ខ្ញុំហាត់ប្រើពាក្យជាមួយមិត្តរួមថ្នាក់ ឬមិត្តភក្តិ<br>ដើម្បីជួយឲ្យខ្ញុំចាំពាក្យបានល្អ។ | ២.៦៧ | ១.១៣ | ២.៦៤ | ១.១៧ |
| ៣៣ | ខ្ញុំមើលវីដេអូ ស្តាប់បទចម្រៀង ឬស្តាប់វិទ្យុជាភាសា<br>អង់គ្លេសដើម្បីស្គាល់ពាក្យថ្មី និងដឹងពីរបៀបប្រើ។ | ២.៨៨ | ១.៣៩ | ២.៧៤ | ១.៤០ |
| ៣៤ | ខ្ញុំតែងតែកត់ត្រាពាក្យថ្មីនៅពេលដែលខ្ញុំមើល<br>ខ្សែភាពយន្ត ឬកម្មវិធីទូរទស្សន៍។ | ២.៣៥ | ១.២៦ | ២.៣៦ | ១.២៨ |

| | | | | | |
|---|---|---|---|---|---|
| ៣៥ | ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យ និងការប្រើប្រាស់របស់វា។ | ៣.៣៨ | ១.២៦ | ៣.១២ | ១.២៨ |
| ៣៦ | ខ្ញុំសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវ ពាក្យដែលខ្ញុំមិនចេះ។ | ៣.៥៤ | ១.១៧ | ៣.៥០ | ១.២២ |
| ៣៧ | ខ្ញុំកត់ចំណាំនៅពេលខ្ញុំឃើញ ពាក្យថ្មី។ | ៣.៣០ | ១.២២ | ៣.១៤ | ១.២៦ |
| ៣៨ | ខ្ញុំដាក់សៀវភៅកត់ពាក្យនៅជាប់ ខ្លួនជានិច្ច។ | ២.៥៣ | ១.២៩ | ២.៦០ | ១.៤២ |
| ៣៩ | ខ្ញុំលេងល្បែង ប្រដេញពាក្យ។ | ២.៤៩ | ១.១៤ | ២.១៥ | ១.២២ |
| ៤០ | ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗ ជាភាសាអង់គ្លេស។ | ២.០៨ | ១.០៥ | ២.០២ | ១.២១ |
| **សរុប** | | ២.៦៣ | ០.៥៨ | ២.៥៧ | ០.៦៦ |

យោងតាមតារាងលើបង្ហាញថា នៅថ្នាក់វិទ្យាសាស្ត្រការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម មានកម្រិតខ្ពស់ចាប់ពី ៣.៥៤ រហូតដល់កម្រិតទាបបំផុត ១.៨៦។ នេះមានន័យថា ចំណុច ៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ គឺមានកម្រិត មធ្យមខ្ពស់ ៣.៥៤ (M=3.54) បន្ទាប់មកទៀតគឺចំណុច ៣៥៖ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យ និងការប្រើប្រាស់របស់វា ដែលមានកម្រិតមធ្យម ៣.៣៨ (M=3.38) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.៣៥ (M=3.35)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨៦ (M=1.86) បន្ទាប់មកមានចំណុចទី២៩៖ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យម ១.៩៣ (M=1.93) និងចំណុចចុងក្រោយគឺ ចំណុច៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៩៤ (M=1.94) ។

ជារួមតាមរាងខាងលើបង្ហាញថាថ្នាក់វិទ្យាសាស្ត្រ ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សតាមរយៈការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្ត្ររៀនតាមរយៈការ បំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុត។

ចំណែកឯនៅថ្នាក់វិទ្យាសាស្ត្រសង្គម ការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម មានកម្រិតខ្ពស់ចាប់ពី ៣.៥១ រហូតដល់ កម្រិតទាបបំផុត ១.៨២។ នេះមានន័យថា ចំណុច ២២៖ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប គឺមានកម្រិត មធ្យមខ្ពស់ ៣.៥១ (M=3.51) បន្ទាប់មកទៀតគឺចំណុច ៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ ដែល

មានកម្រិតមធ្យម ៣.៥០ (M=3.50) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្ត ម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.២៣ (M=3.23)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨២ (M=1.82) បន្ទាប់មកមានចំណុចទី ៦៖ ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ មានកម្រិតមធ្យម ១.៩៩ (M=1.99) និងចំណុចចុងក្រោយគឺ ចំណុច៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ២.០១ (M=2.01) ។

ជារួមតាមរាងខាងលើបង្ហាញថា ថ្នាក់វិទ្យាសាស្ត្រសង្គមការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សតាមរយៈការព្យាយាមចងចាំពាក្យដោយការប្រកប មានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្ត្ររៀនតាមរយៈការបំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុត។

សរុបសេចក្តីមកឃើញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្ស មានភាពខុសគ្នាតិចតួចដោយ ការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់នៅថ្នាក់វិទ្យាសាស្ត្រ ចំណែកឯថ្នាក់វិទ្យាសាស្ត្រសង្គម ការព្យាយាមចងចាំពាក្យដោយការប្រកបមានកម្រិតខ្ពស់។ ដូចគ្នានេះផងដែរ ការប្រើយុទ្ធសាស្ត្ររៀនតាមរយៈការបំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុតរបស់សិស្សថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គមមានភាពដូចគ្នា ។

**តារាងទី៧៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់** (N=៣៥៥)

អ្នកស្រាវជ្រាវដែលក៏ចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិ ដែលរៀននៅបណ្តុំមុខវិជ្ជាផ្សេងគ្នា (ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គម) ជាផ្នែក។

ការស្រាវជ្រាវនេះ អ្នកសិក្សាប្រើឧបករណ៍ស្រាវជ្រាវ ផ្នែកទាំង បួននៃកម្រងសំណួរនោះមាន៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន៖ មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) ទៅតាមផ្នែកនីមួយៗ ។

| ខ្លឹមសារ | វិទ្យាសាស្ត្រ | | | | សង្គម | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដារ | អត្ថន័យ | លំដាប់ | មធ្យម | គម្លាតស្តង់ដារ | អត្ថន័យ | លំដាប់ |
| ១- ការបង្កើតពាក្យ | ២.៦៣ | ០.៧១ | មធ្យម | ៣ | ២.៥៤ | ០.៧៦ | មធ្យម | ៣ |
| ២- ការតាមដានការប្រើពាក្យ | ២.៥១ | ០.៦៧ | មធ្យម | ៤ | ២.៤៩ | ០.៧៤ | ទាប | ៤ |
| ៣- ទំនាក់ទំនងនៃការប្រើពាក្យ | ២.៦៥ | ០.៦២ | មធ្យម | ២ | ២.៦១ | ០.៧១ | មធ្យម | ២ |
| ៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ | ២.៧៤ | ០.៧៧ | មធ្យម | ១ | ២.៦៦ | ០.៨១ | មធ្យម | ១ |
| **សរុបរួម** | **២.៦៣** | **០.៥៨** | **មធ្យម** | | **២.៥៧** | **០.៦៦** | **មធ្យម** | |

តាមតារាងជាផ្នែកខាងលើបានបង្ហាញថា ថ្នាក់វិទ្យាសាស្ត្រ មានកម្រិតខ្ពស់ចាប់ពី ២.៧៤ រហូតដល់ កម្រិតទាប ២.៥១ និងមានកម្រិតមធ្យម ២.៦៣ (M=2.63)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៧៤ (M=2.74) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦៥ (M=2.65) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៦៣ (M=2.63) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៥១ (M=2.51)។

នេះសបញ្ជាក់ឲ្យឃើញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សប្រុសតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែល គ្នាដែលផ្នែកទី ៤ មានកកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៧៤ (M=2.74) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៥១ (M=2.51)។

តារាងដដែលនេះក៏បង្ហាញពីលទ្ធផលតាមផ្នែកនៅថ្នាក់សង្គម មានកម្រិតខ្ពស់ចាប់ពី ២.៦៦ រហូតដល់ កម្រិតទាប ២.៤៩ និងមានកម្រិតមធ្យម ២.៥៧ (M=2.57)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៦៦ (M=2.66) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦១ (M=2.61) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៤ (M=2.54) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៤៩ (M=2.49)។

នេះសបញ្ជាក់ឲ្យឃើញថា ការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សថ្នាក់សង្គមតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែល គ្នាដែលផ្នែកទី ៤ មានកកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៦៦ (M=2.66) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៤៩ (M=2.49)។

ជារួមការសិក្សាខាងលើបង្ហាញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមបណ្តុំមុខវិជ្ជាមានភាពដូចៗ ផ្នែកទី ៤ មានកម្រិតមធ្យមខ្ពស់ជាងគេ រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ។

**តារាងទី៨៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់** (N=៣៥៥)

នៅចំណុចនេះអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃភាពខ្លាំង និងភាពខ្សោយក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិ ចំនួន ៣៥៥ នាក់ ស្រី ១៩២ នាក់ ចំនួន ១០ ថ្នាក់ មកពីវិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ទៅតាមផ្នែកនីមួយៗនៃកម្រងសំណួរជ្រើសរើសផងដែរ។

ឧបករណ៍ស្រាវជ្រាវ ផ្នែកទាំងបួននៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦)ផ្នែកទី២ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) ទៅតាមផ្នែកនីមួយៗ ។

| ល.រ | ខ្លឹមសារ | សិស្សពូកែ | | សិស្សខ្សោយ | |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដារ | មធ្យម | គម្លាតស្តង់ដារ |
| ១ | ខ្ញុំសរសេរពាក្យម្តងហើយម្តងទៀតដើម្បីចងចាំវា។ | ២.៦០ | ១.០៩ | ២.៥៤ | ១.០០ |
| ២ | ខ្ញុំរំលឹកឡើងវិញនូវពាក្យដែលខ្ញុំបានរៀនម្តងហើយម្តងទៀត។ | ២.៩៣ | ១.១៨ | ២.៨៥ | ១.០៩ |
| ៣ | ខ្ញុំសរសេរពាក្យជាបញ្ជីដើម្បីជួយឲ្យខ្ញុំចងចាំវា។ | ២.៤០ | ១.២៤ | ២.៣៦ | ១.២៥ |
| ៤ | ខ្ញុំសួរខ្លួនឯងនៅលើបញ្ជីពាក្យរហូតដល់ខ្ញុំចងចាំវា។ | ២.៥៨ | ១.៣៧ | ២.៣៤ | ១.១៨ |
| ៥ | ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា។ | ៣.៥៣ | ១.២៤ | ៣.២៥ | ១.៣០ |
| ៦ | ខ្ញុំសរសេរពាក្យនៅផ្នែកម្ខាងនៃកាត និងអត្ថន័យនៅម្ខាងទៀតដើម្បីរំលឹកឡើងវិញ។ | ២.១២ | ១.០៣ | ២.០៤ | ១.១៨ |
| ៧ | ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត។ | ១.៨៨ | ១.០៥ | ១.៩៩ | ១.១៤ |
| ៨ | ខ្ញុំស្តាប់ការថតពាក្យជាច្រើនដងដើម្បីជួយខ្ញុំឲ្យចាំពីរបៀបដែលវាបញ្ចេញសំឡេង។ | ២.៧៤ | ១.២៦ | ២.៤៧ | ១.២៤ |
| ៩ | ខ្ញុំបែងចែកជាប្រភេទ (គ្រឿងសង្ហារឹម, ពណ៌ | ២.២៦ | ១.៣៣ | ២.០៤ | ១.២៣ |

| | | | | | |
|---|---|---|---|---|---|
| | ជាដើម) ដើម្បីឲ្យខ្ញុំចងចាំវា។ | | | | |
| ១០ | ខ្ញុំចាំពាក្យដោយភ្ជាប់ជាមួយពេលដែល ខ្ញុំបានរៀន។ | ៣.៣០ | ១.០៦ | ២.៩៨ | ១.១៣ |
| ១១ | ខ្ញុំប្រើពាក្យគន្លឹះ (ភ្ជាប់ពាក្យមួយទៅពាក្យមួយទៀត) ដើម្បីជួយខ្ញុំរៀន។ | ២.៧៩ | ១.៣៤ | ២.៤៦ | ១.២៥ |
| ១២ | ខ្ញុំចាំពាក្យដោយភ្ជាប់ទំនាក់ទំនងវាជាមួយទីតាំងដែលខ្ញុំបានឃើញ។ | ២.៧២ | ១.៣០ | ២.៥៣ | ១.១៨ |
| ១៣ | ខ្ញុំភ្ជាប់ពាក្យដែលទាក់ទងផ្សេងទៀតទៅនឹងអ្វីដែលខ្ញុំកំពុងរៀន។ | ២.៩៥ | ១.២១ | ២.៦៤ | ១.១៧ |
| ១៤ | ខ្ញុំភ្ជាប់រូបភាពទៅនឹងពាក្យដើម្បីជួយខ្ញុំចងចាំវា។ | ២.៥៦ | ១.៤៤ | ២.៥៣ | ១.២១ |
| ១៥ | ខ្ញុំភ្ជាប់ពាក្យទៅនឹងឃ្លា ប្រយោគ ឬអត្ថបទដែលខ្ញុំឃើញ។ | ២.៦៥ | ១.២១ | ២.៤៧ | ១.២៤ |
| ១៦ | ខ្ញុំបង្កើតឃ្លាខ្លីៗ (បង្កើតឃ្លាដើម្បីភ្ជាប់អត្ថន័យ) ដើម្បីឲ្យចងចាំពាក្យ។ | ២.៩៣ | ១.៣០ | ២.៧៥ | ១.៣០ |
| ១៧ | ខ្ញុំភ្ជាប់ពាក្យទៅនឹងពាក្យដែលមានន័យដូច ឬន័យផ្ទុយរបស់វាដើម្បីជួយខ្ញុំចងចាំវា។ | ២.៣៧ | ១.២៣ | ២.៣៩ | ១.២២ |
| ១៨ | ខ្ញុំប្រើពាក្យស្រដៀងគ្នាដើម្បីឲ្យឆាប់ចាំ។ | ៣.១៤ | ១.៣៦ | ២.៦៨ | ១.២៥ |
| ១៩ | ខ្ញុំព្យាយាមភ្ជាប់ពាក្យភាសាអង់គ្លេសទៅនឹងភាសារបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យចងចាំ។ | ៣.២១ | ១.៤២ | ២.៩១ | ១.២២ |
| ២០ | ខ្ញុំចាំពាក្យខ្លះៗតាមវិធីដែលវាផ្លាស់ប្តូរដោយប្រើវេយ្យាករណ៍ជាភាសាអង់គ្លេស។ | ២.៣៥ | ១.១៧ | ២.៤៥ | ១.១៨ |
| ២១ | ខ្ញុំដាក់ក្រុមពាក្យទៅតាមប្រភេទដើម្បីងាយចាំ (សត្វ ការងារ សម្លៀកបំពាក់...)។ | ២.៧២ | ១.២២ | ២.៤៨ | ១.២៦ |
| ២២ | ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ។ | ៣.៧០ | ១.១៩ | ៣.៣៩ | ១.២៥ |
| ២៣ | ខ្ញុំហ្វឹកហាត់ប្រើពាក្យដើម្បីចងចាំវាឲ្យបានប្រសើរជាងមុន។ | ៣.០០ | ១.២៩ | ៣.០២ | ១.២៥ |
| ២៤ | ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ។ | ២.០៩ | ១.១៩ | ១.៨០ | ១.០០ |
| ២៥ | ខ្ញុំសិក្សាពាក្យទាំងអស់ជាមួយរូបភាពដែលបង្ហាញពីអត្ថន័យរបស់វា។ | ២.៦០ | ១.២៤ | ២.២៩ | ១.០៨ |
| ២៦ | ខ្ញុំព្យាយាមកំណត់អត្ថន័យវានៅពេលរៀន | ៣.១៩ | ១.២០ | ២.៧៦ | ១.១៩ |

| | | | | | |
|---|---|---|---|---|---|
| | ដើម្បីឲ្យដឹងថាខ្ញុំចេះវា ឬអត់។ | | | | |
| ២៧ | ខ្ញុំបង្កើតពាក្យចួនដើម្បីជួយ ខ្ញុំឲ្យចងចាំ។ | ២.២១ | ១.៣០ | ២.១៩ | ១.១៨ |
| ២៨ | ខ្ញុំចាំពាក្យដែលមានសំឡេង ស្រដៀងគ្នា។ | ២.៩៣ | ១.២០ | ២.៧៤ | ១.១៦ |
| ២៩ | ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)។ | ២.០៥ | ១.២៧ | ១.៩៨ | ១.១២ |
| ៣០ | ខ្ញុំនិយាយ និងសរសេរពាក្យភាសាអង់គ្លេស ដែលខ្ញុំកំពង់រៀនតាមតែអាចធ្វើបាន។ | ៣.២៨ | ១.២៨ | ៣.១២ | ១.២៤ |
| ៣១ | ខ្ញុំហាត់ប្រើពាក្យថ្មីដោយធ្វើការសន្ទនា ជាមួយមិត្តភក្តិ ឬជនបរទេស។ | ២.៥៨ | ១.២៨ | ២.២៥ | ១.២១ |
| ៣២ | ខ្ញុំហាត់ប្រើពាក្យជាមួយមិត្តរួមថ្នាក់ ឬមិត្តភក្តិ ដើម្បីជួយឲ្យខ្ញុំចាំពាក្យបានល្អ។ | ២.៧៩ | ១.២៨ | ២.៦៤ | ១.១៣ |
| ៣៣ | ខ្ញុំមើលវីដេអូ ស្តាប់បទចម្រៀង ឬស្តាប់វិទ្យុជាភាសា អង់គ្លេសដើម្បីស្គាល់ពាក្យថ្មី និងដឹងពីរបៀបប្រើ។ | ៣.២៦ | ១.៤៣ | ២.៧៤ | ១.៣៨ |
| ៣៤ | ខ្ញុំតែងតែកត់ត្រាពាក្យថ្មីនៅពេលដែលខ្ញុំមើល ខ្សែរភាពយន្ត ឬកម្មវិធីទូរទស្សន៍។ | ២.៥៣ | ១.៣៧ | ២.៣៣ | ១.២៥ |
| ៣៥ | ខ្ញុំប្រើវចនានុក្រមដើម្បីរកមើលអត្ថន័យ និងការប្រើប្រាស់របស់វា។ | ៣.៥៣ | ១.២៦ | ៣.១៩ | ១.២៧ |
| ៣៦ | ខ្ញុំសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវ ពាក្យដែលខ្ញុំមិនចេះ។ | ៣.៧០ | ១.១២ | ៣.៤៩ | ១.២០ |
| ៣៧ | ខ្ញុំកត់ចំណាំនៅពេលខ្ញុំឃើញ ពាក្យថ្មី។ | ៣.២៦ | ១.៤៣ | ៣.២១ | ១.២១ |
| ៣៨ | ខ្ញុំដាក់សៀវភៅកត់ពាក្យនៅជាប់ ខ្លួនជានិច្ច។ | ២.៧២ | ១.៤៤ | ២.៥៥ | ១.៣៦ |
| ៣៩ | ខ្ញុំលេងល្បែង ប្រដេញពាក្យ។ | ២.៧៩ | ១.៤១ | ២.២៣ | ១.១៥ |
| ៤០ | ខ្ញុំព្យាយាមនិយាយ ឬពិពណ៌នារឿងរ៉ាវផ្សេងៗ ជាភាសាអង់គ្លេស។ | ២.៤០ | ១.២៤ | ២.០០ | ១.១២ |
| **សរុប** | | ២.៧៨ | ០.៦៧ | ២.៥៨ | ០.៦២ |

យោងតាមតារាងលើបង្ហាញថា ភាពខ្លាំងក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម មានកម្រិតខ្ពស់ចាប់ពី ៣.៧០ រហូតដល់ កម្រិតទាប បំផុត ១.៨៤។ នេះមានន័យថា ចំណុច ៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ ដែលមាន

កម្រិតមធ្យម ៣.៧០ (M=3.៧០) បន្ទាប់មកទៀតគឺចំណុច២២៖ព្យាយាមចងចាំពាក្យដោយការប្រកប គឺមានកម្រិតមធ្យមខ្ពស់ ៣.៧០ (M=3.70) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.៥៣ (M=3.53)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៨៨ (M=1.88) បន្ទាប់មកមានចំណុចទី២៩៖ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យម ២.០៥ (M=2.05) និងចំណុចចុងក្រោយគឺចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ២.០៩ (M=2.09) ។

ជារួមតាមរាងខាងលើបង្ហាញថា ភាពខ្លាំងរបស់សិស្សក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមរយៈការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់ ចំណែកឯការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀតមានកម្រិតទាបបំផុត។

ចំណែកឯភាពខ្សោយរបស់សិស្ស ក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម មានកម្រិតខ្ពស់ចាប់ពី ៣.៤៩ រហូតដល់ កម្រិតទាបបំផុត ១.៨០។ នេះមានន័យថា ចំណុច ៣៦៖សួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ ដែលមានកម្រិតមធ្យម ៣.៤៩ (M=3.49) បន្ទាប់មកទៀតគឺចំណុច២២៖ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប គឺមានកម្រិត មធ្យមខ្ពស់ ៣.៣៩ (M=3.39) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៥៖ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.២៥ (M=3.25)។ តារាងខាងលើក៏បានបង្ហាញពីកម្រិតទាបបំផុតផងដែរដែលមានចំណុច ២៤៖ខ្ញុំបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨០ (M=1.80) បន្ទាប់មកមានចំណុចទី ២៩៖ ខ្ញុំរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យម ១.៩៨ (M=1.98) និងចំណុចចុងក្រោយគឺ ចំណុច៧៖ខ្ញុំដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៩៩ (M=1.99) ។

ជារួមតាមរាងខាងលើបង្ហាញថា ភាពខ្សោយក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមរយៈការព្យាយាមចងចាំពាក្យដោយការប្រកប មានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្ត្ររៀនតាមរយៈការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀតមានកម្រិតទាបបំផុត។

សរុបសេចក្តីមកឃើញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្ស មានភាពខ្លាំងរបស់សិស្សក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមរយៈការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់ ចំណែកឯ ការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀតមានកម្រិតទាបបំផុត។ រីឯភាពខ្សោយក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាម រយៈការព្យាយាមចងចាំពាក្យដោយការប្រកប មានកម្រិតខ្ពស់ ចំណែកឯការប្រើយុទ្ធសាស្ត្ររៀន

តាមរយៈការដាក់បញ្ចីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀតមានកម្រិតទាបបំផុត។

**តារាងទី៩៖ មធ្យម គម្លាតស្តង់ដារ អត្ថន័យ និង លំដាប់កម្រិតនៃការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ៣៥៥ នាក់** (N=៣៥៥)

ការសិក្សាពីភាពខ្លាំង និងភាពខ្សោយអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិទៅតាមផ្នែកនីមួយៗនៃកម្រងសំណួរជ្រើសរើសផងដែរ។

ការប្រើឧបករណ៍ស្រាវជ្រាវ ផ្នែកនៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១- ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦)ផ្នែកទី២- ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣- ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) អត្ថន័យ និងលំដាប់ ទៅតាមផ្នែកនីមួយៗ ។

| ខ្លឹមសារ | សិស្សពូកែ | | | | សិស្សខ្សោយ | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាត ស្តង់ដារ | អត្ថន័យ | លំដាប់ | មធ្យម | គម្លាត ស្តង់ដារ | អត្ថន័យ | លំដាប់ |
| ១- ការបង្កើតពាក្យ | ២.៦៩ | ០.៧០ | មធ្យម | ៣ | ២.៥៦ | ០.៧៤ | មធ្យម | ៣ |
| ២- ការតាមដានការប្រើពាក្យ | ២.៦៥ | ០.៧២ | មធ្យម | ៤ | ២.៤៨ | ០.៧១ | ទាប | ៤ |
| ៣- ទំនាក់ទំនងនៃការប្រើពាក្យ | ២.៨១ | ០.៧៦ | មធ្យម | ២ | ២.៦០ | ០.៦៦ | មធ្យម | ២ |
| ៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ | ២.៩៦ | ០.៩៤ | មធ្យម | ១ | ២.៦៦ | ០.៧៧ | មធ្យម | ១ |
| **សរុបរួម** | **២.៧៨** | **០.៦៧** | **មធ្យម** | | **២.៥៨** | **០.៦២** | **មធ្យម** | |

តាមតារាងជាផ្នែកខាងលើបានបង្ហាញពីភាពខ្លាំងរបស់សិស្សក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស មានកម្រិតខ្ពស់ចាប់ពី ២.៩៦ រហូតដល់ កម្រិតទាប ២.៦៥ និងមានកម្រិតមធ្យម ២.៧៨ (M=2.78)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៩៦ (M=2.96) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៨១ (M=2.81) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៦៩ (M=2.69) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៦៥ (M=2.65)។

នេះបញ្ជាក់ឲ្យឃើញថា ភាពខ្លាំងរបស់សិស្សក្នុងការប្រើយុទ្ធរៀនវាក្យសព្ទតាមផ្នែកមានកម្រិតមធ្យម ប្រហាក់ប្រហែលគ្នាដែលផ្នែកទី ៤ មានកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៩៦ (M=2.96) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៦៥ (M=2.65)។

តារាងដដែលនេះក៏បង្ហាញពីភាពខ្សោយតាមផ្នែក មានកម្រិតខ្ពស់ចាប់ពី ២.៦៦ រហូតដល់ កម្រិតទាប ២.៤៨ និងមានកម្រិតមធ្យម ២.៥៨ (M=2.58)។ នេះបង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៦៦ (M=2.66) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦០ (M=2.60) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៦ (M=2.56) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៤៨ (M=2.48)។

នេះសបញ្ជាក់ឲ្យឃើញថា ភាពខ្សោយក្នុងការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សតាមផ្នែកមានកម្រិតមធ្យមប្រហាក់ប្រហែលគ្នាដែលផ្នែកទី ៤ មានកម្រិតមធ្យមខ្ពស់ជាងគេ គឺកម្រិតខ្ពស់ត្រឹម ២.៦៦ (M=2.66) រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ គឺកម្រិតមធ្យម ២.៤៨ (M=2.48)។

ជារួមការសិក្សាខាងលើបង្ហាញថា ភាពខ្លាំង និងខ្សោយក្នុងការប្រើយុទ្ធរៀនវាក្យសព្ទរបស់សិស្សមានភាពដូច បើទោះបីមានកម្រិតមធ្យមខុសគ្នា តែវាស្ថិតនៅក្នុងកម្រិតមធ្យម មធ្យមដូចគ្នា។ ផ្នែកទី ៤ មានកម្រិតមធ្យមខ្ពស់ជាងគេ រីឯផ្នែកទី ២ ដែលមានកម្រិតមធ្យមទាបជាងគេ។

### ៤.២- តើមានការប្រើប្រាស់យុទ្ធសាស្ត្រសិក្សាវាក្យសព្ទខុសគ្នារវាងសិស្សរៀនបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម និងសិស្សដែលមានភេទខុសគ្នាឬទេ?

នៅចំណុចនេះអ្នកស្រាវជ្រាវនឹងធ្វើការប្រៀបធៀបនូវការប្រើប្រាស់យុទ្ធសាស្ត្រសិក្សាវាក្យសព្ទភាសាអង់គ្លេសតាមបណ្តុំមុខវិជ្ជា រវាងវិទ្យាសាស្ត្រ និងសង្គម។

### តារាងទី១០ ៖ភាពដូចគ្នា និងភាពខុសគ្នាការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាតាមបណ្តុំវិទ្យាសាស្ត្រ និងសង្គម

អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិតាមបណ្តុំវិទ្យាសាស្ត្រ និងសង្គម។

ការប្រៀបធៀបការប្រើយុទ្ធសាស្ត្រតាមបណ្តុំមុខវិជ្ជា អ្នកស្រាវជ្រាវប្រើឧបករណ៍ស្រាវជ្រាវផ្នែកនៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១- ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២- ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣- ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) តម្លៃ t និង P-value ទៅតាមផ្នែកនីមួយៗ ។

| ខ្លឹមសារ | វិទ្យាសាស្ត្រ | | សង្គម | | t | P-value |
|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដារ | មធ្យម | គម្លាតស្តង់ដារ | | |
| ១- ការបង្កើតពាក្យ | ២.៦៣ | ០.៧១ | ២.៥៤ | ០.៧៦ | ១.២១ | ០.១៧០ |
| ២- ការតាមដានការប្រើពាក្យ | ២.៥១ | ០.៦៧ | ២.៤៩ | ០.៧៤ | ០.២៤ | ០.០៧៧ |
| ៣- ទំនាក់ទំនងនៃការប្រើពាក្យ | ២.៦៥ | ០.៦២ | ២.៦១ | ០.៧១ | ០.៥៦ | ០.១៣៦ |
| ៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ | ២.៧៤ | ០.៧៧ | ២.៦៦ | ០.៨១ | ០.៩៨ | ០.៥៨៧ |
| **សរុបរួម** | **២.៦៣** | **០.៥៨** | **២.៥៧** | **០.៦៦** | **០.៨៩** | ០.០៦០ |

តាមតារាងទី១០ ខាងលើលទ្ធផលបង្ហាញថា សិស្សរៀនបណ្តុំវិទ្យាសាស្ត្រ និងសង្គមប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស ជារួម និងតាមផ្នែកប្រើប្រាស់យុទ្ធសាស្ត្រមិនខុសគ្នាទេ (p>0.0៦០)។ លទ្ធផលនេះអាចពន្យល់បានថា៖ ការប្រើយុទ្ធសាស្ត្ររៀនដូចគ្នានេះដោយសារតែចំនួនម៉ោងសិក្សានៅមធ្យមសិក្សាដូចគ្នា សៀវភៅសិក្សាគោលដូចគ្នា កម្មវិធីសិក្សាដូចគ្នា វិធីសាស្ត្របង្រៀនដូចគ្នា និងគ្រូបង្រៀនភាគច្រើនមិនត្រូវបានបំប៉ននូវវិធីសាស្ត្របង្រៀនថ្មីៗ។ លើសពីនេះទៅទៀតការសិក្សារបស់នៅតាមសាលាហាក់ដូចមិនមានការប្រកួតប្រជែងដោយហេតុតែមុខវិជ្ជាភាសាអង់គ្លេសមិនមែនជាមុខវិជ្ជាកាតព្វកិច្ចនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសក្សាទុតិភូមិ។

ជារួមយើងអាចនិយាយបានថា សិស្សដែលរៀននៅបណ្តុំមុខវិជ្ជាផ្សេងគ្នាមានការប្រើយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសដូចគ្នា។

## តារាងទី១១ ៖ភាពដូចគ្នា និងភាពខុសគ្នាការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាតាមភេទ ប្រុស និងស្រី

ការសិក្សានេះអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិភូមិតាមភេទប្រុស និងស្រីនូវរបៀបរៀនសូត្ររបស់ពួកគេ។

នៅក្នុងការប្រៀបធៀបការប្រើយុទ្ធសាស្ត្រតាមភេទ អ្នកស្រាវជ្រាវប្រើឧបករណ៍ស្រាវជ្រាវផ្នែកនៃកម្រងសំណួរនោះមាន ៖ ផ្នែកទី១- ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២- ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣- ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។

ស្ថិតិដែលប្រើវិភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដារ(Standard deviation) តម្លៃ t និង P-value ទៅតាមផ្នែកនីមួយៗ ។

| ខ្លឹមសារ | ប្រុស | ស្រី | t | P-value |
|---|---|---|---|---|

| | មធ្យម | គម្លាតស្តង់ដារ | មធ្យម | គម្លាតស្តង់ដារ | | |
|---|---|---|---|---|---|---|
| ១- ការបង្កើតពាក្យ | ២.៥៧ | ០.៧៩ | ២.៥៨ | ០.៦៩ | -០.១០ | ០.០៦២ |
| ២- ការតាមដានការប្រើពាក្យ | ២.៤៦ | ០.៧២ | ២.៥៣ | ០.៧០ | -០.៨៣ | ០.៥២៧ |
| ៣- ទំនាក់ទំនងនៃការប្រើពាក្យ | ២.៥៨ | ០.៦៤ | ២.៦៦ | ០.៧០ | -១.១៧ | ០.២១៨ |
| ៤- ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ | ២.៦៣ | ០.៧៩ | ២.៧៦ | ០.៨០ | -១.៥១ | ០.៨៣៧ |
| **សរុបរួម** | **២.៥៦** | **០.៦៣** | **២.៦៣** | **០.៦២** | -១.០៦ | ០.៦៥៥ |

តាមតារាងទី១១ ខាងលើលទ្ធផលបង្ហាញថា សិស្សដែលមានភេទខុសគ្នានៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស ជារួម និងតាមផ្នែកប្រើប្រាស់យុទ្ធសាស្ត្រមិនខុសគ្នាទេ (p>០.០៦៥)។ លទ្ធផលនេះអាចពន្យល់បានថាៈការប្រើយុទ្ធសាស្ត្ររៀនដូចគ្នានេះដោយសារតែចំនួនម៉ោងសិក្សានៅមធ្យមសិក្សាដូចគ្នា សៀវភៅសិក្សាគោលដូចគ្នា កម្មវិធីសិក្សាដូចគ្នា វិធីសាស្ត្របង្រៀនដូចគ្នា និងគ្រូបង្រៀនមិនការបណ្តុះបណ្តាលបន្ថែម ។ ដូចគ្នានេះដែរការសិក្សារបស់សិស្សនៅតាមសាលាហាក់ដូចមិនបានយកចិត្តទុកដាក់ និងមិនមានការប្រកួតប្រជែងដោយហេតុតែមុខវិជ្ជាភាសាអង់គ្លេសមិនមែនជាមុខវិជ្ជាកាតព្វកិច្ចនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសក្សាទុតិភូមិ។

នេះបង្ហាញឲ្យឃើញថា សិស្សដែលភេទផ្សេងគ្នា (ប្រុស និងស្រី) មានការប្រើយុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសដូចគ្នា។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន ការពិភាក្សា និងអនុសាសន៍

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន ការពិភាក្សា និងអនុសាសន៍

## ៥.១- សេចក្តីសង្ខេបលទ្ធផលការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះក្នុងគោលបំណងចង់ស្វែងយល់ និងសិក្សាពីការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ នៅក្នុងនេះផងដែរអ្នកស្រាវជ្រាវបានជ្រើសរើសភាគសំណាកជាសិស្សចំនួនសរុប ៣៥៥ នាក់ ស្រីចំនួន ១៩២ នាក់ បែងចែកជាពីរបណ្តុំមុខវិជ្ជាក្នុងនោះថ្នាក់វិទ្យាសាស្ត្រចំនួន ១៥៦ នាក់ ស្រីចំនួន ៨៦ នាក់ និងថ្នាក់សង្គមចំនួន ១៩៩ នាក់ ស្រីចំនួន ១០៦ នាក់ មកពី វិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ។ ឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានចំនួន ៤០ ចំណុច បែងចែកជា ៤ ផ្នែក៖ ផ្នែកទី១ ការបង្កើតពាក្យ (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦) ផ្នែកទី២៖ ការតាមដានការប្រើពាក្យ (មាន ១១ ចំណុច ចាប់ពី ៧ ដល់ ១៧) ផ្នែកទី៣៖ ទំនាក់ទំនងនៃការប្រើពាក្យ (មាន ១៣ ចំណុច ចាប់ពី ១៨ ដល់ ៣០) និងផ្នែកទី៤ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ (មាន ១០ ចំណុច ចាប់ពី ៣១ ដល់ ៤០)។ ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ សំយោគបញ្ចូលគ្នានូវសំណាកនីមួយៗ ( សិស្សតាមបណ្តុំមុខវិជ្ជា និងភេទ) ដោយផ្តោតសំខាន់ទៅលើការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្ស។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី SPSS សម្រាប់ស្វែងរកចំនួនហ្វ្រេកង់គិតជាភាគរយ Microsoft Word សម្រាប់ធ្វើតារាង & Excel សម្រាប់ធ្វើតារាង រៀបលំដាប់ និងបកស្រាយព័ត៌មាន។

លទ្ធផលនៃការស្រាវជ្រាវសំខាន់ៗអាចបូកសរុបបានដូចខាងក្រោម៖

១- ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្ស មានភាពមិនខុសគ្នាដោយ ការសួរមិត្ត ភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលពួកគេមិនចេះមានកម្រិតខ្ពស់ ៣.៥៤ (M=3.54) នៅថ្នាក់វិទ្យាសាស្ត្រ ចំណែកឯថ្នាក់វិទ្យាសាស្ត្រសង្គម ការព្យាយាមចងចាំពាក្យដោយការប្រកបមានកម្រិតខ្ពស់ ៣.៥១ (M=3.51)។ ដូចគ្នានេះផងដែរ ការប្រើយុទ្ធសាស្ត្ររៀនតាមរយៈការ បំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុតរបស់សិស្សថ្នាក់វិទ្យាសាស្ត្រ ១.៨៦ (M=1.86) និង១.៨២ (M=1.82) ថ្នាក់សង្គមមានកម្រិតទាបដូចគ្នា ។

២- លទ្ធផលបង្ហាញថា សិស្សដែលមានភេទខុសគ្នានៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសតាមរយៈសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែល មិនចេះ មានកម្រិតខ្ពស់(សិស្សប្រុស ៣.៥០ (M=3.50) និងសិស្សស្រី ៣.៥៣ (M=3.53)) ចំណែកឯការប្រើយុទ្ធសាស្ត្ររៀនតាមរយៈ រៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........) មានកម្រិតមធ្យមទាបបំផុត១.៨៧

(M=1.87) សម្រាប់សិស្សប្រុស និងការបំបែកពាក្យជាបុព្វបទ និងបច្ច័យមានកម្រិតទាបបំផុត សិស្សស្រី ១.៨០ (M=1.80)។

## ៥.២-ការពិភាក្សាការស្រាវជ្រាវ

តាមលទ្ធផលស្រាវជ្រាវខាងលើបង្ហាញថា ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម មានលក្ខណៈដូចគ្នាទៅតាមផ្នែកនីមួយៗ ទាំងសិស្សរៀននៅ បណ្តុំមុខវិជ្ជាផ្សេងគ្នា (ថ្នាក់វិទ្យាសាស្ត្រ និងសង្គម - p>0.0៦0) និងសិស្សដែលមានភេទខុសគ្នា (ប្រុស និងស្រី - p>0.0៦៥) Fan(2003)។

ការសិក្សាជាផ្នែកតាមបណ្តុំថ្នាក់វិទ្យាសាស្ត្រ និងសង្គមបង្ហាញថា ការប្រើប្រាស់យុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស ជារួម និងតាមផ្នែកប្រើប្រាស់យុទ្ធសាស្ត្រមិនខុសគ្នាទេ (p>0.0៦0)។ ផ្ទុយពីនេះការឃើញរបស់ Rao and Liu (2011) ក្នុងប្រទេសចិន បង្ហាញថាមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងសិស្សវិទ្យាសាស្ត្រសង្គម និងសិស្សវិទ្យាសាស្ត្រក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀន ដោយបង្ហាញពី (បណ្តុំមុខវិជ្ជាសិក្សា) ជាកត្តាដ៏មានឥទ្ធិពលមួយដែលជះឥទ្ធិពលដល់ការប្រើប្រាស់យុទ្ធសាស្ត្ររបស់អ្នកសិក្សា។ ដោយឡែកនៅកម្ពុជាសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស មានកម្រិតមធ្យមលំអៀងគ្នាតិចតួច តែតម្លៃ p>0.060 មានន័យថាការប្រើយុទ្ធសាស្ត្ររៀនមិនខុសគ្នាទេ។

ការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សតាមភេទ (ប្រុស និងស្រី)មានភាពដូចជារួម និងតាមផ្នែកប្រើប្រាស់យុទ្ធសាស្ត្រមិនខុសគ្នាទេ (p>0.0៦៥)។ ការសិក្សារបស់ Wafa (2003) ក៏បានបង្ហាញថាមិនមានភាពខុសគ្នារវាងការប្រើយុទ្ធ សាស្ត្ររៀនរបស់សិស្សប្រុស និងសិស្សស្រី។ ជាមួយគ្នានេះ Lee's (2007) ក៏បានលើកថាគ្មានភាពផ្សេងគ្នារវាងការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សប្រុស និងសិស្សស្រីផងដែរ។ ការស្រាវជ្រាវរបស់ Wei (2007) ក៏រកមិនឃើញភស្តុតាងនៃភាពខុសគ្នាគួរឲ្យកត់សម្គាល់ក្នុងការប្រើប្រាស់យុទ្ធសាស្ត្ររៀនភាសាបរទេសរបស់សិស្សដែលភេទខុសគ្នាដែរ។ ទន្ទឹមគ្នានេះការលើកឡើងរបស់ Zokaee, Zaferanieh and Naseri (2012) ថាមិនមានភាពខុសគ្នាខ្លាំងរបស់ការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សដែលមានភេទខុសគ្នានោះទេ។ ការសិក្សារបស់ Nicolau N. Manuel (2017) ក៏បានអះអាងថាមិនមានភាពខុសគ្នាទេក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាបរទេសរបស់សិស្សប្រុស និងសិស្សស្រី។ ដូចនេះការរៀនរបស់សិស្សដែលមានភេទខុសគ្នាមានលក្ខណៈមិនខុសគ្នានោះទេ។

លទ្ធនេះអាចនិយាយបានថាការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សដូចគ្នានេះដោយសារ តែចំនួនម៉ោងសិក្សានៅមធ្យមសិក្សាដូចគ្នា សៀវភៅសិក្សាគោលដូចគ្នា កម្មវិធីសិក្សាដូចគ្នា វិធីសាស្ត្របង្រៀនដូចគ្នាដូចគ្នា។ បន្ថែមពីនេះទៀត ការសិក្សារបស់នៅតាមសាលាហាក់ដូចមិនមានការប្រកួតប្រជែង ដោយហេតុតែមុខវិជ្ជាភាសាអង់គ្លេសមិនមែនជាមុខវិជ្ជាកាតព្វកិច្ចនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសក្សាទុតិភូមិ។

## ៥.៣- អនុសាសន៍

### ៥.៣.១. អនុសាសន៍សម្រាប់ការអនុវត្ត

ដើម្បីបង្កើននូវគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេស ក៏ដូចជាការជួយដល់សិស្សក្នុងការប្រើយុទ្ធសាស្ត្ររៀនវាក្យសព្ទភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិឲ្យទទួលគុណវុឌ្ឍិខ្ពស់ អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរមួយចំនួនដល់ភាគីពាក់ព័ន្ធទាំងអស់រួមមាន៖ (១) ក្រសួងអប់រំ យុវជន និងកីឡា ដែលជាអ្នកផលិតនៅកម្មវិធីសិក្សាគោលគួរតែរៀបចំកម្មវិធីសិក្សាឲ្យបានសមស្រប និងស៊ីគ្នាជាមួយសៀវភៅសិក្សាគោល។ (២) មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គួរយកចិត្តទុកដាក់បង្កើតនូវវគ្គសិក្សា ឬបណ្ដុះបណ្ដាលដល់គ្រូបង្រៀន និងតាមដាននូវការអនុវត្តកម្មវិធីសិក្សាដែលក្រសួងបានដាក់ឲ្យប្រើ។ (៣) សាលារៀនត្រូវចូលរួមសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តដើម្បីជំរុញការរៀន និងបង្រៀនប្រព្រឹត្តតាមកម្មវិធីដែលបានកំណត់ដោយក្រសួង។ (៤) គ្រូបង្រៀនគួរតែចូលរួមនូវរាល់សកម្មភាពរបស់សាលាដើម្បីឲ្យដំណើរការរៀន និងបង្រៀនសម្រេចបានតាមវត្ថុបំណងដែលបានកំណត់ និងត្រូវស្វ័យសិក្សាជាប្រចាំ និងស្រាវជ្រាវពីវិធីសាស្ត្រណាដែលថ្មីៗដើម្បីពង្រឹងនូវ គុណវុឌ្ឍិ និង ជំនាញផ្សេងៗបន្ថែមទៀត។ ជំរុញឲ្យមានការលើកទឹកចិត្តដល់សិស្សានុសិស្ស និងបង្ហាញនូវ វិធីសាស្ត្ររៀនល្អៗដើម្បីឲ្យសិស្សឆាប់ចាំ និងឆាប់ចេះសម្រាប់ជាប្រយោជន៍របស់ពួកគេនាពេលអនាគត។

### ៥.៣.២. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវមួយនេះ បានធ្វើឡើងតែទៅលើថ្នាក់ទី ១២ នៅតាមសាលាវិទ្យាល័យចំនួន ៥ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាមប៉ុណ្ណោះ ដូច្នេះលទ្ធផលដែលរកឃើញអាចនៅមានចន្លោះប្រហោងនៅឡើយ ។ ហេតុនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះ គួរតែពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឲ្យបានធំជាងនេះ ប្រសិនបើនៅតែមានបំណងចង់សិក្សានៅក្នុងខេត្តកំពង់ចាមដដែល ឬបណ្ដាខេត្តនានានៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យអ្នកសិក្សាស្រាវជ្រាវក្រោយៗអាចយកប្រធានបទនេះទៅសិក្សានៅតំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនៅតាមបណ្ដាខេត្តនានាផងដែរ ដោយសារតែគុណភាពសាលារៀន គុណភាពគ្រូបង្រៀន និងការប្រើយុទ្ធសាស្ត្រនៃការរៀនភាសាអង់គ្លេសរបស់សិស្សនៅតាមតំបន់នីមួយៗអាចមានភាពខុសគ្នាពីស្ថានភាពរបស់សិស្សនៅក្នុង ស្រុកបាធាយនៃខេត្តកពង់ចាម។

## សេចក្ដីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវអំពី យុទ្ធសាស្ត្រក្នុងការរៀនវាក្យសព្ទភាសាអង់គ្លេសរបស់សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម ជារួមមានការប្រើយុទ្ធសាស្ត្ររៀនរបស់សិស្សមានភាពដូចគ្នាដោយ ការរៀនតាមរយៈ (ចំណុចទី ៣៦) ការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលខ្ញុំមិនចេះ គឺមានកម្រិត មធ្យមខ្ពស់ ៣.៥២ (M=3.52) បន្ទាប់មកទៀតគឺ (ចំណុចទី ២២) ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកប ដែលមានកម្រិតមធ្យម ៣.៤៣ (M=3.43) និងកម្រិតខ្ពស់ចុងក្រោយគឺ (ចំណុចទី ៥) ខ្ញុំអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្ដងហើយម្ដងទៀតដើម្បីឲ្យចាំវា មានកម្រិតមធ្យម ៣.២៨ (M=3.28)។ នៅក្នុងនោះផងដែរ

កម្រិតទាបបំផុតផងដែរ អំពីការប្រើយុទ្ធសាស្ត្ររៀនតាមរយៈ (ចំណុចទី ២៤) ការបំបែកពាក្យជាបុព្វបទ និងបច្ច័យដើម្បីជួយខ្ញុំរៀនវាឲ្យឆាប់ចាំ មានកម្រិតមធ្យម ១.៨៤ (M=1.84) បន្ទាប់មក (ចំណុចទី ៧) ការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នាដើម្បីរៀនវាតាមរបៀបផ្សេងៗទៀត មានកម្រិតមធ្យម ១.៩៧ (M=1.97) និងចំណុចចុងក្រោយគឺ (ចំណុចទី ២៩) ការរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ, .........) មានកម្រិតមធ្យម ១.៩៩ (M=1.99)។

លើសពីនេះទៀតការលទ្ធផលជាផ្នែកក៏បង្ហាញឲ្យឃើញថា ផ្នែកទី ៤៖ ទំនាក់ទំនងពាក្យទៅនឹងអត្ថបទ មានកម្រិតមធ្យម មធ្យមខ្ពស់ជាងគេ ២.៧០ (M=2.70) បន្ទាប់ទៀត ផ្នែកទី ៣៖ ទំនាក់ទំនងនៃការប្រើពាក្យ ដែលមានកម្រិតមធ្យម ២.៦២ (M=2.62) បន្ទាប់មកទៀតផ្នែកទី ១៖ ការបង្កើតពាក្យ ដែលមានកម្រិតមធ្យម ២.៥៨ (M=2.58) ចំណែកឯផ្នែកទី ២៖ ការតាមដានការប្រើពាក្យ ជាផ្នែកមួយដែលមានកម្រិតមធ្យមទាបជាងគេ មានកម្រិតមធ្យម ២.៥០ (M=2.៥0)។

សរុបមកយើងឃើញថា ការសិក្សាពីយុទ្ធសាស្ត្ររៀនវាក្យសព្ទរបស់សិស្សនៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាមបានបង្ហាញឲ្យឃើញពីការប្រើប្រាស់បែបបទរបៀបសិក្សាដូចគ្នា ទាំងសិស្សដែលមានភេទខុសគ្នា និងសិស្សដែលរៀននៅបណ្តុំមុខវិជ្ជាផ្សេងគ្នា ដោយពួកគេប្រើយុទ្ធសាស្ត្រវាក្យសព្ទច្រើនតាមរយៈ ៖ ការសួរមិត្តភក្តិ លោកគ្រូ អ្នកគ្រូនូវពាក្យដែលគេមិនចេះ ការព្យាយាមចងចាំពាក្យដោយការប្រកប និងការអានពាក្យឲ្យឮៗ ឬនឹកក្នុងចិត្តម្តងហើយម្តងទៀត។ ការសិក្សានេះក៏រកឃើញពីយុទ្ធសាស្ត្រដែលពួគេប្រើតិចផងដែរ៖ ការបំបែកពាក្យជាបុព្វបទ និងបច្ច័យ ការដាក់បញ្ជីពាក្យបញ្ចូលតាមលំដាប់ខុសៗគ្នា និងការរៀបពាក្យតាមថ្នាក់ពាក្យ (ឧ. នាម, កិ, គុណ,.........)។

## ឯកសារយោង

– តារាងសំណើរមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៩ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម លេខ ៨០២/១៩ អយក.កច.ប្រឡ។
– សេចក្តីណែនាំ លេខ៖ ៨៤ អយក.សណន.ស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា របស់ក្រសួងអប់រំ ចុះថ្ងៃទី៦ ខែ តុលា ឆ្នាំ២០១៧។
– សេចក្តីណែនាំ លេខ៖ ៨៧ អយក.សណន.ស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា របស់ក្រសួងអប់រំ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០១៦។
– *របាយការណ៍បូកសរុបវាយតម្លៃការងារ អប់រំ យុវជន និងកីឡា ខេត្តកណ្ដាលឆ្នាំសិក្សា២០១៦-២០១៧ និងទិសដៅឆ្នាំសិក្សា ២០១៧-២០១៨.* កណ្ដាល: មន្ទីរអប់រំ យុវជន និង កីឡាខេត្ត កណ្ដាល
– សៀវភៅវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត
– ស្ថិតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
– Amiryousefi, M., & Ketabi, S. (2011). Mnemonic instruction: A way to boost vocabulary learning and recall. *Journal of Language Teaching and Research, 2*, 178-183.
– Asgari, A., & Mustapha, A.B. (2011). The Type of Vocabulary Learning Strategies Used by ESL Students in University Putra Malaysia. *English Language Teaching* 4.2, 84-90.
– Brown, C., & Payne, M. E. . (1994). *Five essential steps of processes in vocabulary learning.* A paper presented at the TESOL convention.Baltimore, Md.
– Cameron, L. (2001). *Teaching languages to young learners*. Cambridge: Cambridge University Press.
– Clayton, T. (2007). *Transition, culture, and language in Cambodia*. In A.B.M. Tsui, & J.W. Tollefson (Eds.).Language policy, culture, and identity in Asian contexts, (pp. 95- 120). Mahwah, NJ: Lawrence Erlbaum Associates
– Crystal, D. (1997). *English as a global lanuage.* Cambridge:Cambridge University Press.
– Crystal, D. (2003). *English as a Global Language.* 2nd edition. Cambridge University Press
– Fan, Y. M. (2003). Frequency of use, perceivedusefulness, and actual usefulness of second language vocabulary strategies: A study of Hong Kong learners. *The Modern Language Journal*, 87(2), 222-241.
– Ghazal, L. (2007). Learning vocabulary in EFL contexts through vocabulary learning strategies. Novitas-Royal, 1(2), 84-91
– Green and Oxford (1995)
– Grosjean. (2010). Bilingual: Life and Reality. Harvard University Press
– Harmer, J. (1991). *The practice of English language teaching*. Longman Handbooks for Language Teachers. London/New York.
– Hatch, E. & Brown, C. (1995).Vocabulary, Semantics, and Language Education. Cambridge: Cambridge University Press.

- Hornby, Albert Sydney. 1995. Oxford Advanced Learner’s Dictionary. New York: Oxford University Press
- Hulstijn, J.H. (1993). When do foreign-language readers look up the meaning of unfamiliar words? The influence of task and learner variables. *The Modern Language Journal*, *77*, 139-147.
- https://infercabulary.com/top-5-reasons-why-vocabulary-matters/
- https://www.k5learning.com/blog/top-5-reasons-learning-vocabulary-important
- Igawa, K. (2008). English Language and its Education in Cambodia, a Country in Transition.
- Jurkoviæ, V. (2006). Vocabulary learningstrategies in an ESP context. Scripta Manent, 2 (1), 23-32.
- Lee, S. (2007). Vocabulary learning strategies of Korean university students: Strategy use, vocabulary size, and gender. English Teaching-Anseonggun-, 62(1), pp. 149-169.
- Lee & Oxford (2008)
- Lewis, M. (1993) *The Lexical Approach. Hove,* England: Language Teaching Publications.
- Meara, P., (2009). Connected Words: Word Association and Second Language Vocabulary Acquisition. John Benjamins Publishing Company, Amsterdam/ Philadelphia
- Ming Wei. (2007) An examination of vocabulary learning of college-level learners of English in China. *The Asian EFL Journal*, 9, 93-114.
- Morin, *R. &* Goebel, J. (2001*). Basic vocabulary instruction teaching strategies or word? Foreign Language Annals, 34* (1), -16.
- Naisbitt, J., & Aburdene, P. (1990). *Megatrends 2000: Ten New Directions for the 1990's*. NY: Avon Books
- Nation, P. (2001). *Learning vocabulary in another language*. Cambridge: Cambridge University Press
- Nicolau N. Manuel (2017) Evaluating Vocabulary Learning Strategies (VLS): Gender differences, the most and least used (VLS) among Angolan EFL Students at the Faculty of Arts (Luanda, Angola)
- Oxford, R. (1992/1993). Language learning strategies in a nutshell: Update and ESL suggestions. *TESOL Journal*, *2*(2), 18-22.
- Oxford, R. L., Burry-Stock, J. (1995). Assessing the use of language learning strategies worldwide with the ESL/EFL version of the strategy inventory of language learning (SILL), *System*, *23*, 1–23.
- Pavicic, 2008: 37
- Pith, C. (1996). *Seminar on ELT in Cambodia. Department of English &Education.* Phnom Penh: Royal University of Phnom Penh
- Rao, Z. & Liu, F. (2011). Effect of Academic Major on Students' Use of Language Learning Strategies: A Diary Study in a Chinese Context. Language Learning Journal, 39 (1), pp. 43-55.
- Richard A. LaBontee, Jr, 2019: Strategic Vocabulary Learning in the Swedish

Second Language Context
- Ruutments, K. (2005). Vocabulary learning strategies in studying English as a foreign language. Unpublished Master's thesis, University of Tartu, Tartu, Estonia
- Schmitt, N. (1997). Vocabulary learning strategies. In Schmitt, N. and McCarthy, M. (eds.) Vocabulary:Descriptive, Acquisition and Pedagogy. Cambridge: Cambridge University Press.
- Schmitt, Norbert. 2000. Vocabulary in Language Teaching. New York: Cambridge University Press.
- Tsai, C. C. & Chang, I. C. (2009). An examination of EFL vocabulary learning strategies of students at the University of Technology of Taiwan. International Forum of Teaching and Studies, 5(2), pp. 32-38.
- Takač, V. P., & Singleton, D. (Eds.).(2008). *Vocabulary learning strategies and foreign language acquisition.*Canada: Multilingual Matters Ltd.
- Tweed, A. D., & Som, M. (2015). English Language Education in Cambodia and international support ahead of ASEAN integration. *IDP Education, 13-40.*
- Vira, N.(2002). Teaching English in Cambodian secondary schools: With a special focus on teachers' preferences towards the improvement of their professional careers in language teaching. *Bulletin, Graduate School of Education, Hiroshima University Part II, 51*, pp. 197-206.
- Wafa A.S. (2003) Language learning strategy use in Palestine, *TESL-EJ, 7*(2). Retrieved from http://www.tesl-ej.org/wordpress/issues/volume7/ej26/ej26a3/
- Wei, M. (2007). An examination of vocabulary learning of college-level learners of English in China. Asian EFL Journal, 9(2), pp. 93-114.
- Wilkins, D. (1972). *Linguistics in language teaching*. London: Arnold. **Wilkins**, **1972**, pp. 111-112) "Lexis is the core or heart of language"
- Zokaee, S., Zaferanieh, E., & Naseri, M. (2012). On the impacts of perceptual learning style and gender on Iranian undergraduate EFL learners' choice of vocabulary learning strategies. English Language Teaching, 5(9), p. 138.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ............ អយក.វិក

*ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

